ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

# អ្នកនាំសារ
The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី២ ថ្ងៃទី០១-៣១ ខែឧសភា ឆ្នាំ២០០៩ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ លេខ ២១

## មាតិកា



យុវជនកំណត់អាជីពដោយឥទ្ធិពលពីខាងក្រៅ
ទំព័រ ៥



ប្រូង់ស្វ័រ ប៉ុងសូង៍ ""កាតូលិកជាសាសនាសកល"
ទំព័រ ៩



ត្រុដិ អត្ថន័យដូចម៉ុងសាយ
ទំព័រ ១៧

# សាសនិកកាតូលិក ក៏ជាជនរងគ្រោះក្នុងរបបខ្មែរក្រហមដែរ



កាលពីចុងខែមីនាកន្លងទៅ ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិកនៅរាជធានីភ្នំពេញបានរៀបចំវេទិកាមួយដើម្បីឲ្យសាសនិកនៃសហគមន៍កាតូលិកបង្ហាញបទពិសោធន៍របស់ពួកគាត់ដែលបានឆ្លងរបបខ្មែរក្រហមស្របពេលដែលអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា កំពុងកាត់ទោសឌុចដែលជាមេគុកទួលស្លែង។ ទំព័រទី១០_១១

SIPAR
សៀវភៅធ្វើអោយអ្នកចេះ
មានលក់នៅតាមបណ្ណាគារ និងតូបលក់សៀវភៅនានា
023 216 001
siparedition@online.com.kh



កម្មវិធីវិទ្យុ



អេម៉ានូអែល សំឡេងពីព្រះសហគមន៏កាតូលិក !
ភ្នំពេញ : FM 99.5 Mhz ម៉ោង ៧:០០-៧:៣០ រាល់យប់ថ្ងៃសៅរ៍
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣០-៨:៣០ រាល់យប់ថ្ងៃសៅរ៍
សៀមរាប: FM 102.5 Mhz ១០:០០-១១:០០ រាល់ថ្ងៃសៅរ៍
កំពង់ធំ : FM 88.5 Mhz ម៉ោង ១២:៣០-១:៣០ ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : FM 100.5 Mhz ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : FM 100.5 Mhz ម៉ោង៦:០០-៧:០០ យប់ថ្ងៃសៅរ៍
កំពត : FM 93.25 Mhz ម៉ោង ៥:០០-៦:០០ រសៀលថ្ងៃសៅរ៍

May-2009.qxd 5/2/2009 9:44 AM Page 2

# រូបថតសម្រាប់លេខនេះ



ប៉ូលីសចរាចរណ៍នៅតែបន្តផាកពិន័យលើអ្នកបើកបរទោចក្រយានដែលគ្មានកញ្ចក់ និងមិនបានពាក់មួកសុវត្ថិភាព។ ចំណែកការបែរកញ្ចក់ចូលមកក្នុងក៏ខុសច្បាប់ចរាចរណ៍ដែរ ដែលប៉ូលីសអាចផាកបាន។ ពេលចូលឆ្នាំថ្មី កន្លងទៅនេះមានមនុស្ស ២៥នាក់ ស្លាប់ និង ១៩០នាក់ រងរបួសដោយគ្រោះថ្នាក់តាមផ្លូវនៅទូទាំងប្រទេស។ **(ឆ្វេង)**

ក្រុមយុវជនខ្មែរកំពុងលេងល្បែងខ្លែងឆាបកូនមាន់ ដែលជាល្បែងមួយក្នុងចំណោមល្បែងប្រជាប្រិយជាច្រើន ដែលជនជាតិខ្មែរនិយមលេងក្នុងឱកាសដ៏រីករាយនាបុណ្យចូលឆ្នាំថ្មី **(ក្រោម)**





យុវជនរាំកំសាន្តជាមួយនិងក្បាច់ប្រពៃណីខ្មែរ មាន រាំវង់ រាំក្បាច់ សារ៉ាវ៉ាន់ និងចូកកំពីស នៅ រមណីយដ្ឋានវត្តភ្នំ រាជធានីភ្នំពេញ **(លើ)**



Photos : Philong

ពេលចូលឆ្នាំអាជ្ញាធរហាមឃាត់ដាច់ខាតចំពោះការលេងជះទឹក ដែលអាចធ្វើឱ្យមានគ្រោះថ្នាក់ចរាចរណ៍ និងរំខានដល់ការរីករាយរបស់ប្រជាពលរដ្ឋ **(ស្តាំ)**



សុខដុមរនីយកម្មរវាងនិយោជក និងនិយោជិក ក្នុងសង្គមប្រជាធិបតេយ្យ គឺកត្តាដើម្បីធ្វើឱ្យសេដ្ឋកិច្ចរីកចម្រើន។ ប៉ុន្តែនេះត្រូវឈរលើផលប្រយោជន៍សមរម្យទៅវិញទៅមក **(ឆ្វេង)**



# វិចារណកថា

## តើធ្វើដូចម្តេចកុំឱ្យមាន ការបង្ហូរឈាមទៀត?



Photo : P. Samphy

លោកប៉ូលរឿង ឆត្រឆ័យ អ្នកសម្របសម្រួលមណ្ឌលផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក (CSC)

ជម្រាបសួរបងប្អូនជាទីស្រឡាញ់! **អ្នកនាំសារ**របស់យើងកំពុងជំរុញឱ្យបងប្អូនប្រជាជនយកចិត្តទុកដាក់ លើដំណើរការរបស់តុលាការខ្មែរក្រហម។ ចំពោះរឿងនេះប្រជាជនមានចំណាប់អារម្មណ៍ខុសប្លែកពីគ្នា។ ខ្លះថាជារឿងហួសពេល។ ខ្លះថា ជារឿងគួរសម។ ខ្លះមិនរវីរវល់។ សម្រាប់គ្រីស្តបរិស័ទ យើងគួរតែចាប់អារម្មណ៍អំពីរឿងនេះដែរ។

ពិតមែនហើយថា ព្រឹត្តិការណ៍នេះហាក់ដូចជាឆ្ងាយពីជីវិតរស់នៅប្រចាំថ្ងៃ។ ប៉ុន្តែរឿងនេះមានសារៈសំខាន់សម្រាប់ប្រជាជាតិខ្មែរតែម្តង។ យើងគួរតែរៀនអំពីបទពិសោធន៍ពីក្នុងព្រឹត្តិការណ៍នេះដើម្បីធ្វើយ៉ាងណាកុំឱ្យមានការបង្ហូរឈាមទៀត។ យុត្តិធម៌ធ្វើឱ្យសង្គមជាតិមានសន្តិសុខ ព្រោះមនុស្សដែលធ្វើបាបប្រជាជន មិនគួរទុកឱ្យបានដៃទេ។ ឃ្លាមួយថា: "សង្គមអត់ល្អដោយសារមនុស្សល្អនៅស្ងៀម" មានន័យថា សង្គមជួបសេចក្តីអាក្រក់ក៏ដោយសារមនុស្សល្អពុំអើពើ ឬចាប់អារម្មណ៍ជួយអន្តរាគមន៍ ដូច្នេះធ្វើឱ្យសង្គមជួបគ្រោះថ្នាក់។

តើព្រះសហគមន៍គិតដូចម្តេច អំពីរឿងនេះ? ខ្ញុំធ្លាប់បានឮថាលោកឌុច អតីតមេគុកទួលស្លែងតែងតែអានព្រះគម្ពីរ។ ព្រះជាម្ចាស់ស្រឡាញ់មនុស្សគ្រប់រូប។ ប៉ុន្តែព្រះអង្គស្អប់អំពើបាបទាំងអស់។ យើងដឹងថា ការទទួលសារភាព ឬដឹងកំហុស ខ្លួនឯង មិនសមនឹងទង្វើដែលធ្វើនោះទេ។ ប៉ុន្តែការសោកស្តាយនូវអំពើបាបនាំឱ្យព្រះជាម្ចាស់បង្ហាញសេចក្តីប្រណីសណ្តោស។ ព្រះបន្ទូលដែលថា: "ត្រូវអត់ទោសឱ្យគេ ចិតសិប ប្រាំពីរដង" (មថ ១៨:២២) នៅតែលាន់ឮក្នុងដួងចិត្តគ្រីស្តបរិស័ទម្នាក់ៗ ឱ្យតែគេចង់កែប្រែគំនិត។ យើងជាគ្រីស្តបរិស័ទត្រូវតែអនុវត្តព្រះបន្ទូលនេះភ្លាមៗ។

ម្យ៉ាងទៀត គួរយើងទុកសេចក្តីវេទនា និងចិត្តខឹងនៅជាមួយសេចក្តីស្រឡាញ់ និងយុត្តិធម៌របស់ព្រះជាម្ចាស់។ បងប្អូនខ្លះមិនអាចបំភ្លេចភាពឈឺចុកចាប់នេះបានឡើយ។ ប៉ុន្តែសម្រាប់អ្នកដែលមានជំនឿ និងជឿលើភាពយុត្តិធម៌ តែងមានសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ជានិច្ច។

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ

Tel/Fax : (855) 23 224 120;

E-mail : csccambodia@gmail.com

Website : www.catholiccambodia.org

ក្រុមប្រឹក្សាភិបាល : លោកអេមីល ដេតម្ប។

អ្នកសម្របសម្រួល : លោកប៉ូលរឿង ឆត្រឆ័យ។ ប្រធាន : លោកលី សុវណ្ណា។

Licence ១៨៣ ពម.ប្រក. / ២៥-មិថុនា-២០០៧

**សេវាកម្មជាទីគាប់ចិត្ត!** **ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកមានបម្រើសេវាកម្មបំប្លែងពីកាសែតវីដេអូ VHS ទៅ VCD និង DVD។ បំប្លែងពីកាសែតម៉ាញ៉េទៅជា CD និង MP3 និងទទួលថតចម្លង CD VCD និងDVD គ្រប់ប្រភេទ។ គ្រប់សេវាកម្មទាំងអស់គិតក្នុងតម្លៃសមរម្យ។ ទូរស័ព្ទ : ០២៣ ៣៧៧ ៩៦០។ សូមអរគុណ!**

## មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក

**អ្នកចូលរួមកម្មវិធីអេម៉ានូអែល {សម្លេងពីព្រះសហគមន៍កាតូលិក} ខែឧសភា**

-ថ្ងៃអាទិត្យទី៤ នៃបុណ្យចម្លង (០៣ ឧសភា): លោកបូជាចារ្យ អូ អ៊ីនដុន មកពីក្រុមសហជីវិនព្រះយេស៊ូ។

-ថ្ងៃអាទិត្យទី៥ នៃបុណ្យចម្លង (១០ ឧសភា): លោកបូជាចារ្យ ង៉ែត វិន័យ អ្នកទទួលខុសត្រូវព្រះសហគមន៍កំពង់ធំ។

-ថ្ងៃអាទិត្យពី៦ នៃបុណ្យចម្លង (១៧ ឧសភា): លោកបូជាចារ្យ បប់ ពិសេ មកពីក្រុមសាសនទូតក្រុងកេបិក ប្រទេសកាណាដា (ព្រះសហគមន៍ផ្សារតូច)។

-ថ្ងៃអាទិត្យទី៧ នៃបុណ្យចម្លង (២៤ ឧសភា): លោកបូជាចារ្យ ពេត្រូ កូមស៍ មកពីក្រុមសាសនទូតនៅយ៉ារ៉ូម៉ាល់ (ព្រះសហគមន៍ចំណោម)។

-ថ្ងៃអាទិត្យទី៨ នៃបុណ្យចម្លង (៣១ ឧសភា): លោកបូជាចារ្យ ហ្វ្រង់ស្វ័រ ប៉ុងស្វ៉ី ពីក្រុមសាសនទូតទីក្រុងប៉ារីស ប្រទេសបារាំង។

**កម្មវិធីវិទ្យុ "ខ្ញុំត្រូវការអ្នក" (FM 99.5 Mhz) ប្រចាំខែឧសភា**

ថ្ងៃទី១១ ឧសភា: ស្រា និងចំណងមិត្តភាព។ ថ្ងៃទី១២ ឧសភា: សប្បាយក្លាយជាទុក្ខ។ ថ្ងៃទី១៨ ឧសភា: គេបារម្ភពីអ្នក? ថ្ងៃទី១៩ ឧសភា: ការដើរលេងតាមសម័យកាល។ ថ្ងៃទី២៥ ឧសភា: ហេតុអ្វីអ្នកកុហក? ថ្ងៃទី២៦ ឧសភា: តើនរណាហ៊ាននិយាយដោយចំហរអំពីការរួមភេទ?។ ប្រធានបទទាំងនេះនឹងមានការចូលរួមបកស្រាយពីវាគ្មិនដែលមានបទពិសោធន៍ និងជំនាញ។ **សូមកុំភ្លេចស្តាប់!**

## សេដ្ឋកិច្ច

# រក្សាលុយនៅផ្ទះ មិនចំណេញដល់សេដ្ឋកិច្ច

**ខាន់ ភីរម្យ**

ប្រធានស្ថាប័នមីក្រូហិរញ្ញវត្ថុមួយ នៅក្នុងប្រទេសកម្ពុជា បានអះអាងថា ពលរដ្ឋគ្រប់រូបគួរដល់ពេលឈប់លាក់លុយនៅក្នុងផ្ទះហើយ ព្រោះវាមិនធ្វើឱ្យចំណេញដល់សេដ្ឋកិច្ច ហើយអាចជួបនឹងហានិភ័យច្រើនជាងយកវាទៅរក្សាទុកនៅស្ថាប័នហិរញ្ញវត្ថុណាមួយដែលត្រឹមត្រូវជាង។


Photo : S. Philong

លោកប៊ុន មុនី ប្រធានស្ថាប័នមីក្រូហិរញ្ញវត្ថុស្ថាប-នាលីមីតធិត មានប្រសាសន៍ថា មកដល់សម័យនេះទៅហើយ ពលរដ្ឋកម្ពុជាត្រូវតែចេះប្រើប្រាស់ និងរក្សាលុយរបស់ខ្លួនឱ្យវាចំណេញនិងមានសុវត្ថិភាពខ្ពស់ ដោយគួរបោះបង់ទម្លាប់ចាស់ចោល។ លោកបានបន្តទៀតថា វាគួរដល់ពេលដែលយើងត្រូវបោះបង់ទម្លាប់រក្សាលុយនៅក្នុងផ្ទះហើយ ព្រោះថា វាអាចនាំមកនូវគ្រោះថ្នាក់ និងងាយស្រួលបាត់បង់។ ប៉ុន្តែបើពួកគេយកលុយទៅរក្សាទុកនៅធនាគារ ឬស្ថាប័នហិរញ្ញវត្ថុណាមួយ ដែលមានទំនុកចិត្ត លុយរបស់ពួកគេនឹងមានសុវត្ថិភាព ហើយអាចចំណេញដល់សេដ្ឋកិច្ច ពីព្រោះវាមានចលនា និងចរន្តលំហូរសាច់ប្រាក់ចុះឡើងនៅក្នុងប្រទេសកាន់តែច្រើន។

លោកបានបន្ថែមថា រក្សាលុយនៅផ្ទះអាចជួបចោរប្លន់ ឬភ្លើងឆេះផ្ទះ ប៉ុន្តែបើយកលុយទៅផ្ញើស្ថាប័នហិរញ្ញវត្ថុណាមួយនោះ។ នេះនឹងឱ្យគាត់ទទួលបានការប្រាក់ លុយមានសុវត្ថិភាព ហើយក៏អាចឱ្យអ្នកផ្សេងទៀតអាចប្រើប្រាស់លុយរបស់គាត់ យកទៅវិនិយោគលើអ្វីផ្សេងៗបានថែមទៀតផង។

យោងតាមការអះអាងរបស់លោកប៊ុន មុនី បានឱ្យដឹងថា ចំពោះលុយអ្នកផ្ញើមួយសន្លឹកទៅក្នុងស្ថាប័នហិរញ្ញវត្ថុ ម្ចាស់លុយក៏អាចចាយបាន អ្នកផ្សេងក៏អាចចាយបាន ហើយម្ចាស់លុយបានការទៀត។

លោកប៊ុន មុនី ក៏បានបញ្ជាក់ថា: "លុយមួយសន្លឹកអាចចាយបានមនុស្សច្រើនគ្នា ប៉ុន្តែបើទុកលុយនៅផ្ទះ មានតែខាតទេ និងមិនស្រួល កណ្ដៀរកាត់"។

យោងទៅតាមវិបសាយរបស់ធនាគារជាតិកម្ពុជា ក៏បានឱ្យដឹងថា រហូតមកដល់ពេលនេះនៅប្រទេសកម្ពុជាមានធនាគារពាណិជ្ជទាំងអស់ ចំនួនជាង២០ ធនាគារឯកទេសចំនួន ៦ និងស្ថាប័នមីក្រូហិរញ្ញវត្ថុចំនួន ១៨ផ្សេងទៀត។ នៅពេលថ្មីៗនេះ ធនាគារជាតិនៃកម្ពុជា ក៏បានយល់ព្រមឱ្យស្ថាប័នទាំងនោះមួយចំនួន អាចទទួលប្រាក់បញ្ញើផងដែរ។

### ពិចារណាលើធនាគារ

លោកប៊ុន មុនី ជាប្រធានក្រុមហ៊ុនស្ថាបនាលីមីតធីត មានប្រសាសន៍ថា: "១០០០រៀលក៏ពលរដ្ឋអាចយកទៅដាក់ផ្ញើស្ថាប័នមីក្រូហិរញ្ញ-វត្ថុបានដែរនៅពេលនេះ"។ លោកបានឱ្យដឹងថា ពីមុនប្រជាពលរដ្ឋអាចជួបការលំបាកខ្លះ នៅក្នុងការយកប្រាក់ទៅរក្សាទុកនៅក្នុងស្ថាប័នហិរញ្ញវត្ថុ ដោយសារតែធនាគារជាតិអនុញ្ញាតឱ្យតែធនាគារពាណិជ្ជ ដែលច្រើនមានទីតាំងនៅទីប្រជុំជនប៉ុណ្ណោះ ដែលអាចទទួលប្រាក់បញ្ញើបាន។ ប៉ុន្តែនាពេលនេះ ស្ថាប័នមីក្រូហិរញ្ញវត្ថុមួយចំនួនបានទទួលអាជ្ញាប័ណ្ណឱ្យមានលទ្ធភាពទទួលប្រាក់បញ្ញើពីប្រជាពលរដ្ឋហើយ។

លោកបានឱ្យដឹងថា ដើម្បីសន្សំបាននៅក្នុងស្ថាប័នរបស់លោក ពលរដ្ឋចាំបាច់ ត្រូវមានអត្តសញ្ញាណប័ណ្ណ ឬសៀវភៅគ្រួសារ ហើយនិងថវិកា ៥ដុល្លារ ដើម្បីបើកគណនី។ បន្ទាប់មកគាត់អាចសន្សំប៉ុន្មានក៏បានដែរ។ លោកបានបញ្ជាក់ថា: "សម្រាប់ស្ថាប័នខ្ញុំ គាត់អាចសន្សំពី៥០០រៀល រហូតដល់រាប់ម៉ឺនដុល្លារបាន"។

## សុខភាព

# ជំងឺមហារីកថ្លើមអាចព្យាបាលជាសះស្បើយ បើរកឃើញទាន់ពេល

**ស្មើកម្ពុជា លេខ ៤៨៩៣**

លោកតេអូ អេងគីយ៉ុង ប្រធានផ្នែកសរីរាង្គរំលាយអាហារនៃដេប៉ាតឺម៉ង់វេជ្ជសាស្ត្រនៃប្រទេសសិង្ហបុរីពោលថា មហារីកថ្លើមមានច្រើនប្រភេទ។ មហា-រីកថ្លើមកើតមកពីដុំសាច់មហារីកកោសិកាថ្លើម។ មហារីកថ្លើមកើត មកពីកោសិកាបំពង់ទឹកប្រម៉ាត់ ឬក៏មហារីកថ្លើម ដែលបណ្ដាលមកពីការរាលដាលមកពីសរីរាង្គផ្សេងៗទៀតមកក្នុងថ្លើមជាដើម។



Photo : DR

មូលហេតុដែលបណ្ដាលឱ្យកើតជំងឺមហារីកថ្លើម គឺដោយសារអ្នកជំងឺមានរលាកថ្លើមវ៉ារ៉ុសប្រភេទ បេ និងគ្រិនថ្លើម។ អ្នកជំងឺមានរលាកថ្លើមវ៉ារ៉ុសប្រភេទ សេ។ អ្នកជំងឺរលាកថ្លើមវ៉ារ៉ុសប្រភេទផ្សេងៗទៀត ឬរលាកថ្លើម ដោយសារជាតិសុរាជាដើម។

លោកតេអូ ក៏បញ្ជាក់ថា អ្នកជំងឺមហារីកថ្លើមមានរោគសញ្ញាដូចជា ស្បែកឡើងលឿងខ្លាំង និងហើមពោះ(ទាចទឹក) និងមានដុំរឹងនៅត្រង់ផ្នែកខាងលើនៃក្រពះ។ អ្នកជំងឺគ្រុនក្ដៅរងា និងមានការពិបាកដោយសារឈឺពោះចំហៀងខាងស្ដាំផ្នែកខាងលើ។ ម្យ៉ាងទៀតការឈឺពោះខ្លាំងដោយសារមានឈាមចូលទៅក្នុងភ្នាសពោះ ដែលធ្វើឱ្យសាច់ដុំ បែកផងដែរ។ លោកវេជ្ជបណ្ឌិតតេអូ អេងគីយ៉ុង បន្ថែមថា ជំងឺមហារីកថ្លើមអាចព្យាបាលជាសះស្បើយបាន។ ប៉ុន្តែអ្នកជំងឺចាំបាច់ក៏ត្រូវទៅជួបលោកវេជ្ជបណ្ឌិតជំនាញដើម្បីរកឱ្យឃើញនូវដុំមហារីកឱ្យទាន់ពេលវេលា។ ជម្រើសក្នុងការព្យាបាលជំងឺមហារីកថ្លើមរួមមានការវះកាត់ថ្លើមការវះកាត់ប្ដូរថ្លើម និងការព្យាបាលដោយកាំរស្មី។ ប្រភេទការព្យាបាលនេះក៏ត្រូវតែផ្អែកទៅតាមស្ថានភាពរបស់អ្នកជំងឺ ស្ថាន-ភាពថ្លើម និងទំហំនៃដុំមហារីកផង។

ជំងឺមហារីកថ្លើមច្រើនកើតមាននៅលើមនុស្សវ័យចាប់ពី៤០ឆ្នាំឡើងទៅ។ ប៉ុន្តែក៏មានករណីមហារីកថ្លើមដែលកើតនៅលើកុមារផងដែរ។



## យុវវ័យ


ការជ្រើសរើសជំនាញសិក្សាគឺជារឿងសំខាន់បំផុតសម្រាប់អនាគត

Photo : P. Samphy

# យុវជនកំណត់អាជីពដោយឥទ្ធិពលពីខាងក្រៅ

**ខាន់ ភីរម្យ**

សម្រាប់ការកំណត់អាជីពដែលជាមាគ៌ាតម្រង់ទិសជីវិតមនុស្សម្នាក់ៗ ចំពោះយុវជនកម្ពុជាភាគច្រើនមិនមែនធ្វើឡើងដោយឆន្ទៈផ្ទាល់ខ្លួនទេ ច្រើនមានឥទ្ធិពលពីកត្តាខាងក្រៅ ដូចជាមិត្តភក្តិ ឬក៏គ្រួសារជួយតម្រង់ផ្លូវ។ នេះបើតាមការអះអាងរបស់យុវនិស្សិតមួយចំនួនដែលកំពុងតែសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សានៅរាជធានីភ្នំពេញ។

កញ្ញាហេង ស្រីពីន និស្សិតឆ្នាំសិក្សា ថ្នាក់មូលដ្ឋានផ្នែកគិលានុបដ្ឋាយិកានៅសកលវិទ្យាល័យចេនឡា បានឱ្យដឹងថា ពីដំបូងឡើយកញ្ញាមិនចង់សិក្សាលើមុខជំនាញនេះទេ។ កញ្ញាមានបំណងចង់សិក្សាលើមុខវិជ្ជាទេសចរណ៍ ក៏ប៉ុន្តែនៅពេលដែលបញ្ចប់ការសិក្សានៅវិទ្យាល័យនៅខេត្តកំពង់ស្ពឺ កញ្ញាសម្រេចចិត្តសិក្សាលើមុខវិជ្ជានេះ ដោយសារគ្រួសាររបស់កញ្ញាមានបំណងចង់ឱ្យកញ្ញាសិក្សាផ្នែកនេះ។ ពួកគេគិតថា កញ្ញាអាចនឹងជួយដល់កិច្ចការនៃគ្រួសារដែលមានឪពុកធ្វើជាគ្រូពេទ្យស្រាប់។

កញ្ញាក៏បានបញ្ជាក់ថា: "បើឱ្យខ្ញុំសម្រេចចិត្តដោយខ្លួនឯងខ្ញុំនឹងរៀនទេសចរណ៍។ ប៉ុន្តែដល់ឪពុកម្ដាយចង់ឱ្យខ្ញុំរៀនពេទ្យ ខ្ញុំក៏សម្រេចចិត្តតាមគាត់"។

បើតាមការអះអាងរបស់ស្រីពិន បើទោះបីជាមុខវិជ្ជាដែលកញ្ញាបានសម្រេចចិត្តនេះ ផ្ទុយពីឆន្ទៈខ្លួនក្ដី នាងក៏មានអារម្មណ៍ចង់រៀន និងចង់ចាប់អាជីពនេះនៅក្នុងពេលអនាគត ជាពិសេសនៅពេលដែលកញ្ញាបញ្ចប់ការសិក្សានាពេលអនាគត។

កញ្ញាបានឱ្យដឹងថា: "ជំនាញទេសចរណ៍ និងពេទ្យមានលក្ខណៈម្យ៉ាងម្នាក់។ ជំនាញទេសចរណ៍ ខ្ញុំគិតថា បានតែសប្បាយទេ តែពេទ្យអាចជួយសង្គ្រោះជីវិតគេបាន ហើយគ្រួសារខ្ញុំក៏ពេញចិត្តដែរ"។

ក្រៅពីស្រីពិនដែលកំពុងរៀនពេទ្យនេះ យុវនិស្សិតមួយរូបទៀត ដែលកំពុងតែសិក្សាផ្នែកគណនេយ្យនៅសាកលវិទ្យាល័យជាតិគ្រប់គ្រង បានឱ្យដឹងថា គ្រួសាររបស់គេ គោរពសិទ្ធិនៅក្នុងការសម្រេចចិត្តរបស់ខ្លួនគេ។ ប៉ុន្តែចំពោះមុខវិជ្ជាដែលគេរៀននេះ គឺដោយសារតែឃើញមិត្តភក្តិគេរៀនច្រើន។

កញ្ញាម្នាក់ដែលមិត្តភក្តិ ហៅថាអេង អះអាង ថា: "ពីក្មេង! ខ្ញុំចង់ជាធ្វើគ្រូ។ ប៉ុន្តែដល់ពេលរើសមហាវិទ្យាល័យរៀន ខ្ញុំក៏យកគណនេយ្យតាមមិត្តភក្តិ"។

កញ្ញា ក៏បានបន្តទៀតថា មិត្តរបស់កញ្ញា ភាគច្រើនមិនពេញចិត្តនឹងមុខជំនាញគ្រូនេះទេ ហើយពួកគេបានព្យាយាមពន្យល់កញ្ញា ដោយហេតុផលផ្សេងៗ ដោយរួមទាំងហេតុផលទីផ្សារការងារ និងប្រាក់ខែនោះផង។ កញ្ញាយល់ស្របតាមពួកគេ។ កញ្ញាបានឱ្យដឹងថា: "គេថា គ្រូប្រាក់ខែតិច គណនេយ្យប្រាក់ខែច្រើន និងងាយស្រួលរកការងារបានធ្វើ"។

យុវជនមួយរូបទៀត ដែលបច្ចុប្បន្ននេះ កំពុងរៀននៅសកលវិទ្យាល័យមួយនោះ បានអះអាងថា រូបគេគឺឯករាជ្យ។ តែទោះបីជាយ៉ាងណាក៏ដោយការសម្រេចចិត្តរបស់គេហាក់ដូចជានៅប្រែប្រួល។

យុវជនទឹម វុត្ថា ជានិស្សិតផ្នែកភាសាអង់គ្លេសនៅសកលវិទ្យាល័យកម្ពុជាបានឱ្យដឹងថា ពីមុនគេមានបំណងចង់ធ្វើការខាងផ្នែកទេសចរណ៍។ ប៉ុន្តែពេលនេះគេចង់ធ្វើជាអ្នកការទូតវិញ។

វុត្ថាបានបញ្ជាក់ថា: "ពីមុន! ខ្ញុំដឹងតែថា កាលណាចេះអង់គ្លេស គេអាចងាយស្រួលធ្វើការខាងផ្នែកទេសចរណ៍ ពីព្រោះភ្ញៀវទេសចរណ៍អន្តរជាតិភាគច្រើន និយាយអង់គ្លេស ប៉ុន្តែនៅពេលនេះខ្ញុំដឹងថាធ្វើជាអ្នកការទូតល្អ និងមានអនាគតល្អជាងដែរ"។

វុត្ថាបានឱ្យដឹងថា មូលហេតុដែលបណ្ដាល ឱ្យរូបគេផ្លាស់ប្ដូរទិសដៅនៃជីវិតរបស់គេយ៉ាងដូច្នេះ ដោយសារតែការស្វែងយល់ពីតម្រូវការទីផ្សារពលកម្ម និងការថ្លឹងថ្លែងសមត្ថភាពផ្ទាល់របស់គេ។

May-2009.qxd 5/2/2009 9:45 AM Page 6



# អាចម៍ប្រចៀវមានតម្លៃដល់ជីវភាព

**ខាន់ ភីរម្យ**



Photo : DR

ប្រចៀវដែលជាសត្វព្រៃមួយប្រភេទ តែអាចក្លាយទៅជាសត្វចិញ្ចឹមនិងមានប្រយោជន៍បំផុតសម្រាប់កសិកម្មនិងគ្រួសារ ។ នេះបើតាមការអះអាងរបស់កសិករមួយរូបនៅក្នុងខេត្តពោធិ៍សាត់ ។

លោកកេងគឹមសេង ប្រជាពលរដ្ឋនៅភូមិអូតាប៉ាង ស្រុកបាកាននាខេត្តពោធិ៍សាត់ អះអាងថា ជាមួយនឹងវត្តមានសត្វប្រចៀវមួយហ្វូងធំ ដែលមានចំនួនប្រមាណជា ១០០០០០ក្បាល លោកអាចផ្គត់ផ្គង់គ្រួសាររបស់គាត់ដែលមានកូនចំនួន ៧នាក់នៅក្នុងបន្ទុកជាមួយជីវភាពមួយដ៏សមរម្យ ។

លោកបានបញ្ជាក់ថា: "ប្រចៀវអាចឱ្យខ្ញុំមានលទ្ធភាពបញ្ជូនកូនទៅរៀននៅឯទីក្រុងភ្នំពេញបាន ៥ នាក់" ។ សព្វថ្ងៃនេះលោកគឹមសេង អាចជាមនុស្សតែម្នាក់គត់នៅកម្ពុជាដែលកំពុងតែចិញ្ចឹមប្រចៀវដើម្បីយកអាចម៍វាមកលក់នៅលើទីផ្សារ ។

បើតាមការឱ្យដឹងរបស់លោកគឹមសេង អាចម៍សត្វប្រចៀវជារបស់មួយដែលមានតម្លៃ ។ វាជាជីធម្មជាតិមួយប្រភេទដែលធ្វើឱ្យដំណាំទទួលបានផលល្អ ហើយមិនធ្វើឱ្យប៉ះពាល់ដីដល់គុណភាពដីដូចជាជីគីមីទេ ។ លោកបានបញ្ជាក់ថា ប្រចៀវមួយក្បាលអាចផ្តល់អាចម៍បាន ៣ ទៅ៤ដុំ នៅក្នុងមួយយប់ ។ ដូច្នេះ១០ម៉ឺនក្បាល គាត់អាចប្រមូលបានបីថ្ងៃ ៣ បាវ ហើយក្នុងមួយបាវមានទម្ងន់ ១០០គីឡូក្រាម គាត់ ដោយគាត់អាចលក់បាន ៤០០០០រៀល ។

លោកគឹមសេងចាប់ផ្តើមចិញ្ចឹមប្រចៀវទាំងអស់នោះតាំងតែពីឆ្នាំ១៩៨២ មកម្ល៉េះ ។ ហើយមកដល់ឆ្នាំ២០០០ ប្រចៀវរបស់គាត់ មានចំនួនរហូតដល់ជិត១លានក្បាលឯណោះ ។ ប៉ុន្តែក្រោយមកវាបានធ្លាក់មកនៅត្រឹមតែ ១០០០០០ក្បាល ដោយសារតែគេលួចចាប់ ពេលពួកវាទៅរកចំណីឆ្ងាយពីផ្ទះ ។

យោងទៅតាមបទពិសោធន៍របស់លោកគឹមសេង ការចិញ្ចឹមប្រចៀវ វាពុំមែនជារឿងដែលពិបាកនិងត្រូវចំណាយលុយច្រើនពេកនោះទេ ។ ដើម្បីចិញ្ចឹមប្រចៀវបាន គឺគេចាំបាច់ត្រូវធ្វើទ្រនំឱ្យពួកវាជាមុនសិន ។ វិធីសាស្ត្រដើម្បីធ្វើទ្រនំនោះគេត្រូវតែរកធ្វើនៅលើដើមត្នោត ដោយមានកម្ពស់ប្រមាណ ពី៧ទៅ ៨ម៉ែត្រ ។ នៅក្នុងកម្ពស់នេះ គេយកឈើដែលជាប់ៗ ទៅចងជាមួយនិងស្លឹកត្នោតព័ទ្ធជុំវិញដោយទុកចន្លោះសម្រាប់ប្រចៀវតោង ។ ហើយដើម្បីឱ្យប្រចៀវហើរចូលមកនៅលើទ្រនំថ្មីនោះ គេចាំបាច់ត្រូវតែស្វែងរកឈើណាដែលប្រចៀវធ្លាប់រស់នៅពីមុនដើម្បីឱ្យប្រចៀវទាំងនោះដឹងក្លិន ។

បរិស្ថាន

## ផ្សោតថយចំនួន

ក្រុមការងារនៃគម្រោងការពារផ្សោតនៅតំបន់មេគង្គកម្ពុជា (CMDCP) បានធ្វើការរាប់ចំនួនត្រីផ្សោត ទឹកសាបចុងក្រោយ នៅកម្ពុជាកាលពីឆ្នាំ



Photo : DR

២០០៧ និងផ្សព្វផ្សាយឆ្នាំ២០០៨ ថា តួលេខចុងក្រោយបង្ហាញថា ផ្សោតមានចំនួន ៦១ក្បាល ។ តួលេខនេះ គឺត្រូវបានធ្វើការសន្និដ្ឋានក្រោយពេលដែល CMDCP បានចំណាយពេលធ្វើដំណើរតាមដងទន្លេមេគង្គក្នុងចម្ងាយ ១៩០គីឡូម៉ែត្រ គឺពីព្រំដែនឡាវមកខេត្តក្រចេះ ដើម្បីធ្វើការស្រាវជ្រាវពីពពួកត្រីផ្សោតចុងក្រោយមានឈ្មោះអ៊ីរ៉ាវ៉ាឌីដែលមាននៅសេសសល់ក្នុងទឹកសាបនៃព្រះរាជាណាចក្រកម្ពុជានៅឡើយ ។

ដោយគេធ្វើការវិភាគទៅលើរូបថតចំនួន៤៣៨៣ សន្លឹកដែលត្រូវបានរើសតាមការបរិច្ឆេទ និងតាមទីកន្លែងថត គេអាចឃើញរូបថតផ្សោតចំនួន ៦១ ក្បាល ។ គេអាចចំណាំពួកវាតាមរយៈរាងរៅ ទំហំ សម្បុរ ស្បែក សម្លាក និងតាមព្រុយខ្នងរបស់ពួកវា ។ តាមរយៈនេះគេអាចធ្វើការសន្និដ្ឋានថា ចំនួនផ្សោតមានការធ្លាក់ចុះយ៉ាងច្រើន ព្រោះតាមការលើកឡើង របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្ហាញថា ត្រីផ្សោតមានចំនួន ១២៧ ក្បាលកាលពីឆ្នាំ២០០៥ ។

បើតាមអ្នកស្រាវជ្រាវបានឱ្យដឹងថា ត្រីផ្សោតនៅទន្លេមេគង្គកំពុងទទួលការគំរាមកំហែង យ៉ាងធ្ងន់ធ្ងរ ដែលធ្វើឱ្យចំនួនពួកវាស្ថិតនៅក្នុងកម្រិតទាប ។ អនាគតនៃពពួកត្រីផ្សោតពិតជាគួរឱ្យព្រួយបារម្ភ ដោយសារទទួលរងនូវការគំរាមកំហែងពីការអភិវឌ្ឍន៍ធនធានមនុស្សដែលចេះតែកើនឡើង ។

**www.ka-set.info**





# ធនាគារស្រូវជួយដោះស្រាយកសិករលើបញ្ហាស្បៀង

**ជាត សំភី**

តាំងតែពីឆ្នាំ២០០៥ មក អង្គការការីតាសបានជួយណែនាំ និងដឹកនាំបង្កើតកម្មវិធីធនាគារស្រូវ ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍របស់សហគមន៍ ជាពិសេសជួយដល់ជនក្រីក្រនៅតាមមូលដ្ឋានភូមិជនបទដាច់ស្រយាល ។ តួយ៉ាងកម្មវិធីធនាគារស្រូវរបស់អង្គការការីតាសនៅខេត្តកណ្តាលត្រូវបានបង្កើតឡើងសម្រាប់ស្រុកពីរ គឺស្រុកល្វាឯម និងស្រុកកណ្តាលស្ទឹង ដោយគេសង្កេតឃើញ ជីវភាពរបស់ប្រជាជនមានការខ្សត់ខ្សោយជាងគេ ។



នៅភូមិព្រះធាតុ ជង្រុកធ្វើពីឈើដែលជួយឧបត្ថម្ភសម្រាប់ធ្វើធនាគារស្រូវនៅក្នុងភូមិ និងអ្នកចាត់ចែងអង្ករក្នុងជង្រុក

លោកឆាយ ម៉េង ប្រធានកម្មវិធីអភិវឌ្ឍន៍សហគមន៍នៃអង្គការការីតាស រៀបរាប់ឱ្យដឹងថា គោលបំណងសំខាន់នៃកម្មវិធីធនាគារស្រូវគឺមានច្រើន ។ ទីមួយ គឺដើម្បីជួយសម្រាល ដល់ការលំបាករបស់ប្រជាកសិករក្រីក្រ ។ ទីពីរដើម្បីផ្គត់ផ្គង់ពូជស្រូវឱ្យដល់ប្រជាកសិករដែលមានមុខរបរធ្វើស្រែ ។ ទីបីគឺធ្វើឱ្យមានពូជស្រូវល្អៗសម្រាប់ផលិតស្រូវ ។ ទីបួនកាត់បន្ថយការខ្ចីពីឈ្មួញខាងក្រៅ ដែលមានអត្រាការខ្ពស់ ។ ទីប្រាំដើម្បីបង្កើនឱ្យមានទិន្នផលខ្ពស់ ។ ទីប្រាំមួយ ដើម្បីបង្កើនឱ្យមានស្បៀងច្រើននៅក្នុងគ្រួសារ និងទីប្រាំពីរ ដើម្បីដោះស្រាយការខ្វះខាតរបស់កសិករនៅចុងរដូវបង្កបង្កើនផល ។

លោកឆាយ ម៉េង ក៏បានបន្តទៀតថា រហូតមកដល់ពេលនេះធនាគារស្រូវនៅខេត្តកណ្តាលដែលបង្កើតឡើងនៅស្រុកពីរនោះបានគ្របដណ្តប់លើ៦ឃុំ និង ១៣ភូមិ នៅក្នុងនោះប្រជាជនដែលបានទទួលផលប្រយោជន៍ពីកម្មវិធីនេះ គឺមានប្រមាណ ២៥០ គ្រួសារ ដែលមានមនុស្ស ១០០០នាក់ ។

លោកឆាយ ម៉េង បាននិយាយថា សម្រាប់កម្មវិធីធនាគារស្រូវនេះ គឺប្រគល់ឱ្យគណៈកម្មការគ្រប់គ្រងជង្រុកស្រូវនៅតាមភូមិជាអ្នកគ្រប់គ្រង ។ រីឯការីតាសជាអ្នកណែនាំ និងគាំទ្រកម្មវិធី ។

លោកឆាយ ម៉េង អះអាងថា: "បច្ចុប្បន្ននេះកម្មវិធីធនាគារស្រូវកំពុងដំណើរការ បានយ៉ាងប្រសើរ ដោយសារតែស្រូវក្នុងជង្រុក មានការកើនឡើង ។ យើងយកការស្រូវ ២០% ចំពោះស្រូវសម្រាប់ហូប និង ៥០% ចំពោះស្រូវពូជ ។ សមាជិកធនាគារស្រូវអាចខ្ចីស្រូវរបស់យើង ប៉ុន្តែបើគាត់ មិនបង្វិលសងមកវិញ គាត់គ្មានលទ្ធភាពខ្ចីទៀតទេ ។ ម្យ៉ាងទៀតកសិករអាចយកស្រូវ មកដាក់សន្សំក្នុងជង្រុកស្រូវនេះដែរ ។ ប៉ុន្តែយើងគ្មានការស្រូវជូនគាត់ទេ" ។

## "បើគាត់ខ្វះខាត យើងក៏មានការអនុគ្រោះពន្យាឱ្យ..."

ធនាគារស្រូវត្រូវបានគ្រប់គ្រងដោយគណៈកម្មការមួយនៅឯក្នុងភូមិមូលដ្ឋានតែម្តង ។ គណៈកម្មការនោះមានសមាជិក ៣នាក់ គឺមានប្រធានម្នាក់ អនុប្រធានម្នាក់ និងបេឡាម្នាក់ ។ សមាជិកធនាគារ ឬជង្រុកនេះ ត្រូវបានជ្រើសរើសដោយការប្រជុំរវាងសមាជិកធនាគារស្រូវនិងបុគ្គលិកអង្គការការីតាសដើម្បីឱ្យចាត់ចែងដំណើរការជង្រុកស្រូវក្នុងភូមិ ។

លក្ខខណ្ឌរបស់សមាជិកដែលអាចក្លាយជាគណៈកម្មការគ្រប់គ្រងធនាគារស្រូវមានដូចជា ត្រូវមានសមត្ថភាព មាននូវការជឿជាក់ មានគេគោរព និងកោតសរសើរច្រើននៅក្នុងភូមិ មានទំនួលខុសត្រូវស្ថានភាពគ្រួសារល្អ និងចរិតលក្ខណៈល្អ ។

អ្នកស្រីយ៉ែម នួន អាយុ៥៤ឆ្នាំ ជាបេឡានៃធនាគារស្រូវ និយាយថា កាលពីឆ្នាំ២០០៥ ការីតាសក៏បានជួយស្រូវ ៤៥០ គីឡូក្រាម ឥឡូវនេះស្រូវ នៅក្នុងជង្រុកបានកើនដល់បីតោនហើយ ។ តែអ្នកស្រីបន្តថា បញ្ហារបស់យើង គឺបងប្អូននៅទីនេះអ្នកខ្លះមានការខ្វះខាតមែនទែន ដែលមិនអាចបង្វិលស្រូវសង



Photos : P. Samphy

អ្នកស្រីហែម ព្រឹង

មកវិញ ឱ្យបានទាន់ពេលវេលា ។ ដូច្នេះបើគាត់ខ្វះខាត យើងមានការអនុគ្រោះ និងពន្យាពេល ។ អ្នកស្រីក៏ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អង្គការការីតាសដែលបានជួយឱ្យមានកម្មវិធីនេះ ។

ចំណែកអ្នកស្រីហែម ព្រឹង អាយុ៦០ឆ្នាំ ជាប្រធានធនាគារស្រូវនៅក្នុង ភូមិព្រះធាតុ ឃុំរលួស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល មានប្រសាសន៍ថា នៅភូមិរបស់អ្នកស្រី មានសមាជិកធនាគារស្រូវ ២៦ គ្រួសារ ដែលមានប្រជាជន ៥៦នាក់ ។ អ្នកស្រីបានបញ្ជាក់ថា: "ខ្ញុំមានអារម្មណ៍រីករាយយ៉ាងខ្លាំងក្នុងការរួមចំណែកជួយដល់គ្រួសារខ្ញុំ ក៏ដូចជាប្រជាជននៅក្នុងសហគមន៍របស់ខ្ញុំឱ្យមានការរីកចម្រើន និងអភិវឌ្ឍន៍ឈានទៅមុខដូច្នេះ" ។

May-2009.qxd 5/2/2009 9:45 AM Page 8



## គណបក្សប្រជាជនតែងតាំងបេក្ខភាពនាយករដ្ឋមន្ត្រី

យោងតាមស្មារតីនៃអង្គមហាសន្និបាតគណៈកម្មាធិការកណ្តាល លើកទី៣៤ អាណត្តិទី៥ កាលពីថ្ងៃទី២៥ ខែមេសា ដែលមានសមាជិកចូលរួមទាំងអស់ចំនួន ៥៦៤នាក់ បានសម្រេចតែងតាំងសម្តេចហ៊ុន សែន ដែលជាអនុប្រធានគណបក្ស នៅតែជាបេក្ខជននាយករដ្ឋមន្ត្រីសម្រាប់ការបោះឆ្នោតអាណត្តិក្រោយ ហើយក៏បានសម្រេចបន្ថែមបេក្ខជនសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ថ្មីនៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ៦រូប បន្ថែមលើសមាជិក ដែលមានស្រាប់ចំនួន ២៩រូប កាលពីមុន។ សមាជិកថ្មីទាំងនេះ មានលោកគាត ឈន់ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លោកទេព ងន អនុប្រធានទីពីរនៃព្រឹទ្ធសភា លោកយឹម ឆៃលី ឧបនាយករដ្ឋមន្ត្រី លោកគន់ គីម អគ្គបញ្ជាការរងកងទ័ព លោកនេត សាវឿន អគ្គស្នងការនគរបាលជាតិ និងលោកមាស សុភា អគ្គមេបញ្ជាការរងរបស់កងទ័ព។

## សមាជិកគណបក្សប្រឆាំងអាចត្រូវដកអភ័យឯកសិទ្ធិ

លោកស្រីមួរ សុខហួរ អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី ត្រូវមេធាវីរាជរដ្ឋាភិបាលប្តឹងទៅលើការប្រកាសមួយរបស់លោកស្រីថា នឹងប្តឹងសម្តេចហ៊ុន សែន ពីបទបរិហា-កេរ្តិ៍។ លោកឱម យិនទៀង ទីប្រឹក្សារបស់សម្តេចហ៊ុន សែន បានអះអាងកាលពីថ្ងៃទី២៤ ខែមេសា ថា ពាក្យបណ្តឹងបានទៅដល់តុលាការ បន្ទាប់ពីលោកស្រីសុខហួរ បានអះអាងថា នឹងប្តឹងសម្តេចហ៊ុន សែន ពីបទបរិ-ហារកេរ្តិ៍។ ចំពោះដំណើរការផ្លូវច្បាប់លើពាក្យបណ្តឹងនេះ លោកបន្តថា សមាជិកគណបក្សប្រជាជនបានត្រៀមខ្លួនដើម្បីដកអភ័យឯកសិទ្ធិរបស់លោកស្រីក្នុងករណីមានសំណើពីតុលាការ។ រឿងរ៉ាវនេះបានកើតឡើងក្រោយពេលដែលប្រមុខរដ្ឋាភិបាលកម្ពុជា បានរិះគន់ស្ត្រីម្នាក់ដោយមិនបញ្ចេញឈ្មោះថា ពូកែនាំប្រឌិតរឿង "ស្ត្រីនោះបានរត់ទៅឱបគេសោះ តែបែរជាចោទប្រកាន់គេថាប្រឡេះឡេវអាវរបស់ខ្លួនទៅវិញ"។

## ក្រសួងសុខាភិបាលកំពុងបារម្ភអំពីជំងឺគ្រុនឈាម

បើតាមរបាយការណ៍របស់ក្រសួងសុខាភិបាលកាលពីពេលថ្មីៗនេះ បានបង្ហាញថា ចាប់ពីដើមខែមករា មកដល់ត្រឹមខែមេសា ឆ្នាំ២០០៩នេះ មានអ្នកជំងឺ ៧៥០នាក់ ដែលជាកុមារដែលក្នុង នោះមានពីរនាក់បានស្លាប់ដោយសារជំងឺគ្រុនឈាម។ លោកវេជ្ជបណ្ឌិតង៉ាន់ ចន្ទា ប្រធាននាយកដ្ឋានប្រឆាំងជំងឺគ្រុនឈាមនៃក្រសួងសុខាភិបាលបានធ្វើការផ្តាំផ្ញើថា: "ខ្ញុំសូមឱ្យបងប្អូនប្រជាជនទាំងអស់ធ្វើការប្រុងប្រយ័ត្ន និងរៀបចំផ្ទះសម្បែងឱ្យបានស្អាតល្អ ដើម្បីកុំឱ្យមានទឹកដក់ ដែលជាហេតុបង្កឱ្យកើតជាមូសខ្លា ដែលជាភ្នាក់ងារចម្លងជំងឺគ្រុនឈាម"។ លោកវេជ្ជបណ្ឌិតបានបន្ថែមទៀតដែរថា នៅឆ្នាំនេះ ក្រសួងសុខាភិបាលបានត្រៀមថ្នាំអាបែតចំនួន១២០តោន ដើម្បីធ្វើការចែកចាយទៅតាមបណ្តាខេត្តទាំងអស់ទូទាំងប្រទេសដោយឥតគិតថ្លៃ។ សូមរំឭកផងដែរថា កាលពីឆ្នាំ២០០៨ មានមនុស្ស៩៥៤២នាក់ ដែលជាជនរងគ្រោះបានឆ្លងជំងឺគ្រុនឈាម។


Photo : DR

**អាគីប**

## ថៃបរាជ័យក្នុងការរៀបចំកិច្ចប្រជុំកំពូលអាស៊ាន


Photo : DR

ប្រទេសថៃបានបរាជ័យនៅក្នុងការរៀបចំកិច្ចប្រជុំកំពូលអាស៊ាន និងប្រទេសដៃគូនានាកាលពីថ្ងៃទី១១ខែមេសា ឆ្នាំ២០០៩។

ទីភ្នាក់ងារព័ត៌មានអេភីបានឱ្យដឹងថា លោកអាភីស៊ីត វីចាជីវ៉ា បានប្រកាសលុបចោលកិច្ចប្រជុំកំពូលរវាងមេដឹកនាំអាស៊ានទាំង១០ និងប្រទេសដៃគូក្នុងតំបន់ គឺមានមកពីប្រទេសចិន ជប៉ុន កូរ៉េខាងត្បូង ឥណ្ឌា អូស្ត្រាលី និងញូវសេឡេន ក្រោយពេលបាតុករគាំទ្រអតីតនាយករដ្ឋមន្ត្រីថាក់ស៊ីនអុកឡុក។

បន្ទាប់ពីលុបចោលកិច្ចប្រជុំដ៏មានសារៈសំខាន់នេះ លោកអាភីស៊ីតបានដាក់ទីក្រុងបាងកក និងខេត្តជុំវិញមួយចំនួនឱ្យស្ថិតនៅក្នុងភាពប្រកាសអាសន្ន និងបានបង្ក្រាបក្រុមបាតុករប្រឆាំងរហូតដល់មានការបាត់បង់ជីវិត និងរបួសជាច្រើនថែមទៀតផង។

ក្នុងឋានៈខ្លួនជាប្រធានអាស៊ាន ថៃបានគ្រោងរៀបចំកិច្ចប្រជុំនេះតាំងតែពីខែធ្នូ ឆ្នាំ២០០៨មកម្ល៉េះ។ ប៉ុន្តែបានពន្យាពេលរហូតដោយសារតែវិបត្តិនយោបាយ។ ទោះបីជាយ៉ាងណាបន្ទាប់ពីបរាជ័យនៅក្នុងកិច្ចប្រជុំខែមេសានេះ ប្រទេសថៃកំពុងតែស្វែងរកការរៀបចំការប្រជុំជាថ្មី នៅក្នុងរង្វង់ខែមិថុនាខាងមុខនេះ។

## អាមេរិក និងម៉ិកស៊ិក ភ័យនឹងជំងឺផ្តាសាយជ្រូកដែលកំពុងរីកសាយ

ជំងឺគ្រុនផ្តាសសាយជ្រូកកំពុងតែរីករាលដាលនៅប្រទេសម៉ិក-ស៊ិក និងអាមេរិក និងបានសម្លាប់មនុស្សប្រមាណជា ១៥២នាក់រហូតដល់ថ្ងៃទី២៦ ខែមេសា។

ឆ្លើយតបនឹងការរីករាលដាលនេះ ក្រុមមន្ត្រីរបស់ប្រទេសទាំង២ និងអង្គការសុខភាពពិភពលោក កំពុងតែចាត់វិធានការទប់ទល់នឹងការរីករាលដាលនេះ។ អង្គការសុខភាពពិភពលោកបានអះ-អាងថា ជំងឺនេះបានសម្លាប់ជីវិតមនុស្សប្រមាណ ១៥២នាក់ និងឆ្លងទៅមនុស្សចំនួន ៩៤៣នាក់ ក្នុងប្រទេសម៉ិកស៊ិក។ ចំណែកឯនៅអាមេរិកវិញ ក្រុមមន្ត្រីជំនាញក៏បានអះអាងថា ជំងឺផ្តាសាយនេះឆ្លងដល់មនុស្ស៧នាក់។ មេរោគដែលបង្កជាជំងឺនេះត្រូវបានគេសង្ស័យថាជាប្រភេទមេរោគ H1N1។

លោកអែនចេល គ័រដូវ៉ា ជារដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រទេសម៉ិកស៊ិក បានអះអាងថា វាគឺជាប្រភេទមេរោគវីរុសម្យ៉ាង ដែលបានកើតចេញពីសត្វជ្រូក និងបានចម្លងទៅមនុស្សមួយចំនួន។

**ខាន់ ភីរម្យ**





# ហ្វ្រង់ស្វ័រ ប៉ុងសូដ៍ : "កាតូលិកជាសាសនាមានលក្ខណៈសកល"

**ខាន់ ភីរម្យ**

*លោកបូជាចារ្យជាតិបារាំងហ្វ្រង់ស្វ័រ ប៉ុងសូដ៍ អ្នកទទួលខុសត្រូវមណ្ឌលវប្បធម៌កាតូលិកកម្ពុជា បានស្គាល់ប្រពៃណីខ្មែរច្រើន ព្រោះលោកបានចូលមកកម្ពុជាតាំងតែពីឆ្នាំ១៩៦៥មក។ លោកបានផ្តល់បទសម្ភាសន៍មួយទាក់ទងនឹងការគោរពប្រណិប័តន៍សាសនាកាតូលិកតាមប្រពៃណីខ្មែរ។*


លោកបូជាចារ្យហ្វ្រង់ស្វ័រ ប៉ុងសូដ៍ ផ្តល់បទសម្ភាសន៍អំពីរបៀបគោរពតាមប្រពៃណីខ្មែរក្នុងគ្រិស្តសាសនាកាតូលិក

**អ្នកនាំសារ : តើហេតុអ្វីព្រះសហគមន៍កាតូលិកនៅកម្ពុជានិយមប្រើប្រាស់ប្រពៃណីខ្មែរដើម្បីផ្សារភ្ជាប់ខ្លួននៅក្នុងសង្គមខ្មែរ ?**

**លោកប៉ុងសូដ៍**: នៅខាងគ្រិស្តសាសនា យើងជឿថា យើងមានព្រះបិតាតែមួយ ដែលជាបិតានៃមនុស្សទាំងអស់។ ដូច្នេះមនុស្សទាំងអស់ គ្រប់ភាសា គ្រប់អារ្យធម៌ អាចគោរពព្រះអង្គ ជាព្រះបិតារបស់ខ្លួនតាមអារ្យធម៌ខ្លួន។ ព្រះយេស៊ូគឺជាជនជាតិយូដា។ ខ្ញុំគឺជាជនជាតិបារាំង។ ខ្ញុំក៏គោរពព្រះយេស៊ូរបៀបបារាំង។ រីឯពលរដ្ឋខ្មែរក៏អាចគោរពតាមប្រពៃណីខ្មែរដូចគ្នា។ ជាក់ស្តែងពេលដែលយើងធ្វើការថ្វាយអភិបូជា។ យើងបានប្រើប្រាស់ធូបមកអុជ នៅមុខឈើឆ្កាង និងទៀនជ័យរបស់យើង។ ហើយជាមួយគ្នានោះ យើងបានគូររូបព្រះយេស៊ូ និងព្រះនាងម៉ារីតាមសិល្បៈខ្មែរ ហើយក៏បានសាងសង់ជាព្រះវិហារមួយចំនួន ដែលមានកំពូលស្រួចៗ តាមរបៀបខ្មែរ ដើម្បីឱ្យគ្រិស្តបរិស័ទជាជនជាតិខ្មែរ យល់ថា គ្រិស្តសាសនារបស់គេ មិនមែនជាសាសនារបស់បរទេសឡើយ និងជឿថា នេះគឺជាសាសនារបស់ប្រជាជនតាមកន្លែងដែលគេរស់នៅ។

**អ្នកនាំសារ : តើវាមានទំនាស់នៃភាពខុសគ្នាទេក្នុងការអនុវត្តជំនឿ នាខណៈពេលដែលសាសនាតែមួយតែមានរបៀប និងវិធីសាស្ត្រអនុវត្តខុសៗគ្នា តាមទីកន្លែង និងតាមអារ្យធម៌ផ្ទាល់ខ្លួនបែបនេះ ?**

**លោកប៉ុងសូដ៍**: ខ្មែរ! គេគោរពតាមខ្មែរ។ ចិន គេធ្វើតាមចិន។ អឺរ៉ុបតាមអឺរ៉ុប។ នេះជាភាពសកលនៃសាសនាកាតូលិក។ មុខងាររបស់យើង គឺធ្វើឱ្យព្រះយេស៊ូកើតជាមនុស្សសម្រាប់ទាំងអស់គ្នាគឺមិនមែនសម្រាប់ជាតិសាសន៍ណាមួយឡើយ។

**អ្នកនាំសារ : ចុះប្រសិនបើនៅពេលដែលពួកគេត្រូវចូលរួមក្នុងពិធីធំមួយជាលក្ខណៈអន្តរជាតិ តើពួកគេអាចអនុវត្តជំនឿរបស់គេតាមវិធីណាទៅវិញ ?**

**លោកប៉ុងសូដ៍**: វាអាស្រ័យនៅលើទីកន្លែង។ ជាក់ស្តែង បើយើងធ្វើមហាសន្និបាតនៅកម្ពុជា គឺយើងធ្វើតាមកម្ពុជា។ ហើយប្រសិនបើមានមហាសន្និ-បាតសកលនៅពេលនោះ គេប្រើតាមរបៀបអឺរ៉ុបដោយប្រើភាសាអង់គ្លេសជាសំខាន់។

**អ្នកនាំសារ: តើសហគមន៍កាតូលិកតម្រូវឱ្យអ្នកដែលមានជំនឿថ្មីៗ បំភ្លេចចោលនូវជំនឿដែលពួកគេធ្លាប់អនុវត្តជាប្រពៃណីជាយូរមកហើយឬយ៉ាងណា ?**

**លោកប៉ុងសូដ៍** : គោរពតាមប្រពៃណី មានន័យថា គោរពតាមរបៀបខ្មែរ។ ប៉ុន្តែបើសិនជាគេជឿលើព្រះយេស៊ូហើយនោះ គេគឺមិនអាចគោរពសាសនាដ៏ទៃទៀតឡើយ។

**អ្នកនាំសារ : សាសនិកកាតូលិកមួយចំនួនដូចជាមានជំនឿលើសាសនាផ្សេងៗ នៅក្នុងពេលតែមួយ តើលោកមានចំណាប់អារម្មណ៍យ៉ាងណាដែរ ?**

**លោកប៉ុងសូដ៍**: សូមទោស! អ្នកដែលមានជំនឿពីរមិនមែនជាកាតូលិកទេ។ យើងទទួលស្គាល់ថានៅក្នុងប្រទេសកម្ពុជា ប្រជាជនភាគច្រើន ចាត់ទុកថាព្រះពុទ្ធ គឺជាព្រះបរមគ្រូ។ ប៉ុន្តែព្រះពុទ្ធសាសនា គឺប្លែកពីគ្រិស្តសាសនា។


Photos : S. Philong

នៅឆ្នាំ១៩៦២ មហាសន្និបាត វ៉ាទីកង់ទី២ បានអនុញ្ញាតឱ្យអ្នកដែលមានជំនឿទាំងអស់គោរពសាសនាកាតូលិកតាមអារ្យធម៌រៀងៗខ្លួន។ ដូច្នេះការសំពះបានក្លាយជាកាយវិការមួយយ៉ាងសំខាន់ក្នុងការគោរពព្រះយេស៊ូរបស់គ្រិស្តបរិស័ទខ្មែរ។

## សហគមន៍កាតូលិក និងកំណែទម្រង់

ព្រះសហគមន៍កាតូលិកបានមកដល់ប្រទេសកម្ពុជាតាំងពីឆ្នាំ១៥៥៥មកម្ល៉េះ គឺប្រហែលជាក្រោយពុទ្ធសាសនានិកាយហីនយាន ៣០០ឆ្នាំ និងក្រោយសាសនារបស់បងប្អូនឥស្លាម ១០០ឆ្នាំ។ ប៉ុន្តែនៅក្នុងពេលនោះ កាតូលិកហាក់ដូចជាមិនមានការរីកចម្រើនសោះ។ រហូតដល់ឆ្នាំ១៩៦២ ក្រោយពីមហាសន្និបាតវ៉ាទីកង់ទី២ ដឹកនាំដោយសម្តេចប៉ាបយ៉ូហានប៉ូលទីពីរ ទើបព្រះសហគមន៍កាតូលិកបានរីកចម្រើនសន្សឹមៗ។ ដោយសារតែមហាសន្និបាតនោះ បានអនុញ្ញាតឱ្យអ្នកដែលមានជំនឿទាំងអស់គោរពតាមអារ្យធម៌រៀងៗខ្លួន។ ពីមុន គឺគេហាក់ដូចជាបង្ខំឱ្យគោរពតាមបែបអឺរ៉ុប។

May-2009.qxd 5/2/2009 9:45 AM Page 10



# សាសនិកកាតូលិក ក៏ជាជនរងគ្រោះនៃរបបខ្មែរ ក្រហមដែរ

**ខាន់ ភីរម្យ**

ក្នុងចំណោមជនរងគ្រោះ ពីរបបខ្មែរក្រហម ដែលកំពុងតែតាមដានលើដំណើរការ របស់សាលាក្តីខ្មែរក្រហម សាសនិកនៃសហគមន៍កាតូលិក ដែលគឺជាជនរងគ្រោះដែរនោះ កំពុងតែតាមមើលដំណើរការរបស់សាលាក្តីនេះយ៉ាងយកចិត្តទុកដាក់ផងដែរ ។ ការឈឺចាប់របស់ពួកគាត់ នៅក្នុងរបបខ្មែរក្រហម បានត្រូវបង្ហាញឡើងតាមរយៈវេទិកាមួយ ដែលរៀបចំឡើង ដោយការិយាល័យប្រព័ន្ធផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិកនៅទីក្រុងភ្នំពេញ កាលពីចុងខែមីនា ឆ្នាំ២០០៩កន្លងទៅនេះ ។

បើយោងទៅតាមអ្វីដែលពួកគាត់បានបង្ហាញនោះ សហគមន៍អ្នកកាន់សាសនាកាតូលិកទាំងអស់ក៏ដូចជាប្រជាពលរដ្ឋកម្ពុជាទូទៅដែរ គឺសុទ្ធតែត្រូវបានរងគ្រោះពីរបបខ្មែរក្រហម ។ ពួកគាត់បានត្រូវពួកខ្មែរក្រហមជម្លៀសចេញពីផ្ទះសំបែង ក្រោយពេលដែលពួកគេបានដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ ។ ពួកគាត់បានត្រូវខ្មែរក្រហមបង្ខំឱ្យធ្វើពលកម្មហួសកម្លាំង ហូបមិនឆ្អែត ធ្លាក់ខ្លួនឈឺគ្មានថ្នាំសង្កូវដើម្បីព្យាបាល ទទួលទារុណកម្ម សម្លាប់ និងត្រូវបានបង្ខំឱ្យបោះបង់ជំនឿ ដូចជាអ្នកកាន់ពុទ្ធសាសនា ព្រមទាំង សាសនាដ៏ទៃទៀតដែរ ។

លោកស្រីម៉ាលីស គណៈកម្មាធិការព្រះសហគមន៍សន្តយ៉ូសែបហៅផ្សារតូច បានឱ្យដឹងថា នៅក្នុងថ្ងៃទី១៧មេសា ឆ្នាំ១៩៧៥ ក្រោយពេលដែលទាហានខ្មែរក្រហមចូលទីក្រុងភ្នំពេញ គាត់ និងគ្រួសារបានត្រូវជម្លៀសទៅកាន់ខេត្តភាគពាយ័ព្យនៃប្រទេស ។ លោកស្រីបញ្ជាក់ថា: “ខ្ញុំត្រូវគេបង្ខំ ឱ្យចាកចេញពីផ្ទះទាំងរបួសដោយសារអំបែងគ្រាប់ ហើយដើរថ្មើរជើងរហូតដល់កន្លះខែ មុននឹងមានឡានមកដឹក” ។ លោកស្រីត្រូវបានជម្លៀសទៅភូមិមួយ គេហៅថាភូមិក្រហមកក្នុងខេត្តក្រចេះ បន្ទាប់មកទៅតំបន់ភ្នំដែលជាតំបន់គ្រុនចាញ់ដ៏ខ្លាំងក្លា ។ ទីនោះ គេចាប់ស្វាមីគាត់យកទៅធ្វើបាប និងធ្វើពលកម្មយ៉ាងធ្ងន់ធ្ងរ ។ ប៉ុន្តែសំណាងល្អ! គ្រួសាររបស់គាត់អាចគេចផុតពីសេចក្តីស្លាប់ទាំងអស់គ្នា នៅខណៈដែលសាច់ញាតិរបស់គាត់ជាច្រើនមិនមានសំណាងឡើយ ។ លោកស្រីអះអាងថា: “ព្រះជាម្ចាស់ដូចជាបានជួយសង្គ្រោះគ្រួសាររបស់លោកស្រីអ៊ីចឹង” ។



Photo : S. Philong

លោកអភិបាល បូជាចារ្យ និងគ្រីស្តបរិស័ទ សុទ្ធតែចូលរួមចែករំលែកបទពិសោធន៍ឈឺចាប់ក្នុងរបបខ្មែរក្រហម

## សហគមន៍សាសនិកកាតូលិក និងរបបខ្មែរក្រហម

**នៅក្នុងរបបខ្មែរក្រហម អ្នកដែលមានជំនឿលើកាតូលិកមិនតិចទេ ដែលបានស្លាប់ ក្នុងនោះក៏មានលោកអភិបាលនៃព្រះសហគមន៍មួយរូបផងដែរ។**

**លោកឆ្មារ សាឡាស អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានបាត់បង់ជីវិតដោយសារតែធ្វើពលកម្មលើសកម្លាំង នៅឆ្នាំ១៩៧៧ បន្ទាប់ពីលោកបានត្រូវជម្លៀសទៅតាំងគោក ស្រុកបារាយ ខេត្តកំពង់ធំ។ លោកឆ្មារ សាឡាស បានទទួលមុខងារជាអភិបាលជំនួសលោកអ៊ីវ រ៉ាមូស នៅក្នុងថ្ងៃទី១៤មេសា ឆ្នាំ១៩៧៥។ មុនរបបខ្មែរក្រហម គ្រីស្តបរិស័ទកាតូលិកនៅកម្ពុជាត្រូវបានប៉ាន់ស្មានថា មានចំនួន ៣០០០០នាក់។ ប៉ុន្តែក្រោយរបបនេះ ចំនួនបានធ្លាក់ចុះនៅមិនដល់១០០០០នាក់ផង។ ក្រោយពេលដែលប្រទេសកម្ពុជាមានសេរីភាពខាងជំនឿឡើងវិញ គ្រីស្តបរិស័ទមានចំនួនប្រមាណ ១៥០០០នាក់។**

ចំណែកអ្នកស្រីប៊ី ក៏ក្លាយជាស្ត្រីមេម៉ាយកូន ៦នាក់ដល់សព្វថ្ងៃនេះ គឺដោយសារតែប៉ុលពតបានយកប្តីរបស់គាត់ទៅសម្លាប់ ។

លោកអ៊ីវ រ៉ាមូស អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងមកប្រទេសកម្ពុជាតាំងតែពីឆ្នាំ១៩៦៣ ។ លោកផ្តល់សក្ខីភាពថា បានឃើញនូវទុក្ខវេទនាជាច្រើនរបស់ជនជាតិខ្មែរ និងសហគមន៍អ្នកកាន់សាសនាកាតូលិក ដែលបានជួបប្រទះ នៅក្នុងសម័យខ្មែរក្រហមនៅពេលដែលលោក និងជនបរទេសមួយចំនួនទៀតត្រូវទាហានខ្មែរក្រហមបង្ខំឱ្យចាកចេញពីប្រទេស តាមផ្លូវគោកពីទីក្រុងភ្នំពេញទៅ កាន់ប្រទេសថៃ ។ លោកអភិបាលបញ្ជាក់ដែរថា: “ក្រៅពីលោកអភិបាលឆ្មារ សាឡាស ដែលខ្ញុំដឹងថា ត្រូវពួកប៉ុលពតសម្លាប់នោះ សាសនិករបស់សហគមន៍កាតូលិកផ្សេងៗ ក៏ជាជនរងគ្រោះដូចជាសាសនិកសហគមន៍ខ្មែរដទៃទៀតដែរ” ។



លោកអភិបាលបន្តថា របបខ្មែរក្រហមជារបបមួយដែលមានលក្ខណៈប្លែកពីរបបផ្សេងៗទៀត ដោយសារតែរបបនេះ បានលុបចោលរចនាសម្ព័ន្ធសង្គមផ្សេងៗ ដោយរួមទាំងរចនាសម្ព័ន្ធគ្រួសារផងដែរ ។ ពួកគេហាក់ដូចជាចង់បង្កើតនូវមនុស្សថ្មីមួយ ។ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបង្ខំមនុស្សទាំងអស់ ចេញពីទីក្រុង ហើយបង្ខំឱ្យធ្វើពលកម្មយ៉ាងទម្ងន់ ។ លោកអភិបាល ប្រាប់ឱ្យដឹងថា ក្រោយពេលដែលលោកត្រូវគេបណ្តេញចេញពីស្ថានទូតបារាំងនៅតាមផ្លូវពីភ្នំពេញទៅអារញ្ញប្រាថេតប្រទេសថៃ លោកបានមើលឃើញ មានសាកសពជាច្រើននៅតាមដងផ្លូវ ហើយមានមនុស្សរាប់ពាន់នាក់កំពុងតែធ្វើការនៅតាមវាលស្រែយ៉ាងស្ងាត់ស្ងៀមជាមួយនិងសម្លៀកបំពាក់ខ្មៅ ក្នុងនោះក្មេងៗនិងអតីតព្រះសង្ឃក៏បានត្រូវគេបង្ខំឱ្យធ្វើការទាំងអស់គ្នាផងដែរ ។ លោកក៏បញ្ជាក់ដែរថា: “ស្នាមញញឹមរបស់ប្រជាជនខ្មែរនាសម័យនោះគឺបាត់អស់រលីង” ។ លោកដឹងរឿងនេះច្បាស់ នៅពេលដែលលោកបានត្រូវគេជម្លៀសដើរកាត់ភូមិមួយ ក្នុងខេត្តបាត់ដំបង ដោយថ្មើរជើង ។ នៅពេលនោះ គាត់បានសុំទឹកពីស្ត្រីម្នាក់ទទួលទាន ប៉ុន្តែស្ត្រីរូបនោះមិនឆ្លើយតបឡើយ គឺទាល់តែមានការយល់ព្រមពីទាហាននៅក្បែរនោះសិន ទើបបានគាត់ឱ្យទឹកយើងហូបទាំងទឹកមុខស្រងូតស្រងាត់ ។ លោកសម្គាល់ថា : “ស្ត្រីរូបនោះបាត់បង់អស់ស្នាមញញឹម ។ខ្ញុំក៏គិតភ្លាមថាខ្មែរហាក់ដូចជាបាត់បង់នូវអត្តសញ្ញាណនិងស្នាមញញឹមអស់ហើយ” ។ ខណៈពេលដែលពលរដ្ឋកម្ពុជា កំពុងប្រឈមមុខនឹងទុក្ខវេទនាទាំងអស់នេះពិភពខាងក្រៅ ពិសេស អន្តរ-ជាតិហាក់ដូចជាមិនបានដឹងឮអំពីបញ្ហានេះទាល់តែសោះ ។ លោកអភិបាលក៏បញ្ជាក់ទៀតថា : “ពេលទៅដល់ ក្រុងបាងកក ប្រទេសថៃ ខ្ញុំមានអារម្មណ៍ថា ពិភពខាងក្រៅ ហាក់ដូចជាមិនបានដឹងអ្វីសោះដែលបានកើតមាននៅក្នុងប្រទេសកម្ពុជា” ។

ក្រៅពីលោកអភិបាលអ៊ីវ រ៉ាមូស លោកបូជាចារ្យមួយរូបទៀត ដែលបានចូលមកកាន់ប្រទេសកម្ពុជាតាំងតែមុនសម័យខ្មែរក្រហមមកកាន់អំណាចមួយរូបទៀត ក៏បានអះអាងដូចគ្នានេះដែរ ។

លោកប៉ុងសូដឺ ដែលជាបូជាចារ្យមួយរូប និងត្រូវបានទាហានខ្មែរក្រហមជម្លៀសជាមួយលោកអ៊ីវ រ៉ាម៉ូសដែរនោះ អះអាងថា: “ខ្ញុំបានព្យាយាមប្រាប់ពិភពលោកថា ខ្មែរក្រហមសម្លាប់មនុស្ស ប៉ុន្តែគេអត់ជឿខ្ញុំទេ ។ ទាំងអង្គការសហប្រជាជាតិ ក៏អត់ជឿដែរ” ។ លោកបន្តថា ក្រោយពួកប៉ុលពតបង្ខំឱ្យចាកចេញពីកម្ពុជា នាថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៥ លោកបានទៅនិយាយ នៅទូរទស្សន៍បារាំងថា ខ្មែរក្រហមបណ្តេញពលរដ្ឋចេញពីទីក្រុង ប៉ុន្តែគ្មានអ្នកណាជឿទេ ។ នៅពេលនោះលោកក៏បានខិតខំប្រមែប្រមូលឯកសារជាច្រើនបន្ថែមទៀត និងបានសហ-ការជាមួយកាសែតល្បីៗ ដោយនិយាយថាបដិវត្តន៍កម្ពុជាកើតឡើងដោយការឈឺចាប់ជាទីបំផុត ប៉ុន្តែនៅតែអត់មានអ្នកជឿសោះ ។ ក្រោយមក លោកបានសរសេរដាក់កាសែតឡឺម៉ុងថា ពួកប៉ុលពតបានសម្លាប់ជីវិតមនុស្សជាង ១លាននាក់ ប៉ុន្តែគ្មាននរណាចាប់អារម្មណ៍ ។ ថ្ងៃទី១៥ កញ្ញា ឆ្នាំ១៩៧៨ គាត់ក៏បាននិយាយម្តងទៀតក្នុងសន្និសីទមួយរបស់អង្គការសហប្រជាជាតិក្រុងហ្សឺណែវ ក៏គ្មាននរណាជឿថា ខ្មែរក្រហមបានសម្លាប់មនុស្សដដែល ។

លោកអះអាងទៀតដែរថា ក្រៅពីគ្មានអ្នកណាជឿហើយនោះ ពិភពលោកដោយរួមនិងអង្គការសហ-ប្រជាជាតិផង គឺនៅគាំទ្ររបបខ្មែរក្រហមដែលដឹកនាំ ដោយប៉ុលពតនេះថែមទៀតផង ក្រោយពេលដែលរបបនេះដួលរលំទៅហើយនោះ ។

លោកបញ្ជាក់ថា : “នៅក្រោយពេលដែលទាហានវៀតណាមបានចូលមកកាន់ប្រទេសកម្ពុជាសហ-ប្រជាជាតិ អាមេរិក និងអឺរ៉ុប នៅតែគាំទ្រដល់ខ្មែរក្រហមរហូតដល់ឆ្នាំ១៩៨៩ ។ គេគាំទ្រខ្មែរក្រហមអស់រយៈពេល ១៤ឆ្នាំ” ។

ពាក់ព័ន្ធនឹងរឿងខ្មែរក្រហមនេះ លោករ៉ូប៊ែរត៍ ប៊ុទី សហព្រះរាជអាជ្ញាប្រចាំសាលាក្តីខ្មែរក្រហមបានឱ្យដឹងថា រឿងខ្មែរក្រហមជារឿងរ៉ាវប្រវត្តិសាស្ត្រមួយរបស់កម្ពុជា ហើយអ្វីដែលកើតមានឡើងនៅសម័យនោះ ក៏ជារឿងរ៉ាវពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រផងដែរ ។ មកដល់ពេលនេះមេដឹកនាំខ្មែរក្រហម ៥នាក់បានកំពុងតែត្រូវចាប់ខ្លួនដើម្បីជំនុំជម្រះ ។ ជនទាំង៥នាក់ដែលត្រូវគេចាប់ខ្លួន គឺមានខៀវ សំផន ប្រមុខរដ្ឋរបស់ខ្មែរក្រហម លោកនួន ជា ជាប្រធានសភា លោកអៀង សារី ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស ប្រពន្ធរបស់គាត់អៀង ធីរិទ្ធ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច នៃរបបខ្មែរក្រហម និងឌុច ដែលជាអតីតមេគុកទួលស្លែង ។

លោកប៊ីទី បញ្ជាក់ថា ឌុចនឹងត្រូវកាត់ទោសអំពីបទដែលគាត់បានធ្វើនៅឯមន្ទីរឃុំឃាំង ស២១ ហើយ ៤នាក់ទៀតនឹងត្រូវកាត់ទោសពីអ្វីៗទាំងអស់ដែលបានកើតមានទូទាំងប្រទេសសម័យខ្មែរក្រហម ។

### ដំណើរការសាលាក្តីខ្មែរក្រហម

**លោករ៉ូប៊ែរត៍ ប៊ុទី សហព្រះរាជអាជ្ញានៃសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម មានប្រសាសន៍ថា សាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមកំពុងដំណើរការ និងអាចបញ្ចប់នៅឆ្នាំ២០១១។ លោកបញ្ជាក់ថា: “ឌុចចាប់ទទួលនូវការវិនិច្ឆ័យទោសកាលពីថ្ងៃទី៣០ មីនា ប៉ុន្តែ៤នាក់ទៀតអាចនឹងដំណើរការចុងឆ្នាំ”។ បើទោះបីជាកាំង ហ្គិចអៀវ ហៅឌុច បានត្រូវកំពុងទទួលការកាត់ទោស។ ប៉ុន្តែមតិមួយចំនួនហាក់ដូចជាគិតថា សាលាក្តីនេះដំណើរការយឺតយ៉ាវ។ ពាក់ព័ន្ធនឹងបញ្ហានេះ លោកប៊ុទីអះអាងថា គេចាំបាច់ត្រូវការពេលវេលាច្រើនដើម្បីសិក្សា និងវិភាគចំពោះគ្រប់បញ្ហា។ លោកបញ្ជាក់ថា: “គ្រាន់តែករណីឌុច សាលាក្តីត្រូវការពេល១ឆ្នាំដើម្បីប្រមូលឯកសារ”។ នៅក្នុងសម័យខ្មែរក្រហមមានមន្ទីរឃុំឃាំងរហូតដល់ទៅ ២១កន្លែងដែលដូចជាគុកទួលស្លែង។ គេត្រូវអានឯកសារ ១៦០០០០ទំព័រ និងសម្ភាសន៍សាក្សី ៣០០នាក់។ រីឯឯកសារត្រូវការបកប្រែដើម្បីជួយចៅក្រមធ្វើការវិនិច្ឆ័យ។**

May-2009.qxd 5/2/2009 9:45 AM Page 12



# សុង កុសល : “សម្ដេចប៉ាបគាំទ្រលុបបំបាត់គ្រាប់មីន”

**លី សុវណ្ណា**

កញ្ញាសុង កុសល ជាទូតរបស់យុវជន និងជនពិការកម្ពុជា បានចូលរួមយុទ្ធនាការលុបបំបាត់គ្រាប់មីន នៅក្រុងរ៉ូម ប្រទេសអ៊ីតាលី កាលពីថ្ងៃទី១ ដល់ទី៣ ខែមេសា កន្លងទៅ ។

នេះជាមោទនភាពដ៏ធំផងដែរសម្រាប់កុសលដែលត្រូវបានជ្រើសរើសដើម្បីចូលរួម ក្នុងនាមជាជនរងគ្រោះ ដោយសារគ្រាប់មីនពីប្រទេសកម្ពុជា ដើម្បីបានទៅចូលរួមក្នុងយុទ្ធនាការលុបបំបាត់គ្រាប់មីននេះ ។ ក្នុងដំណើរទៅចូលរួមនេះដែរ កញ្ញាកុលសបានបញ្ជាក់ថា នាងក៏បានទៅចូលគាល់សម្ដេចប៉ាបរួមជាមួយប្រធានក្រុមយុទ្ធនាការលុបបំបាត់គ្រាប់មីនរបស់អ៊ីតាលី ដើម្បីទូលថ្វាយនូវសកម្មភាពនៃយុទ្ធនាការ នៅប្រទេសកម្ពុជាយើង ។ សម្ដេចប៉ាបបេណេឌីក ទី១៦ ក៏មានប្រសាសន៍ លើកទឹកចិត្តឱ្យបន្តសកម្មភាពនេះតទៀតរហូតបានជោគជ័យ ។ ព្រះអង្គគាំទ្រទាំងស្រុងលើសកម្មភាពនេះ ។

នៅក្នុងកិច្ចប្រជុំជាមួយក្រសួងការបរទេសអ៊ីតាលី កញ្ញាបានខិតខំយ៉ាងអស់ពីសមត្ថភាពដើម្បីបង្ហាញនូវទុក្ខលំបាករបស់ជនរងគ្រោះដោយសារតែគ្រាប់មីន ជាពិសេសនៅប្រទេសកម្ពុជា ។ យុវតីទូត ជនពិការវ័យ២៤ឆ្នាំរូបនេះ បន្តថា កញ្ញាបានអំពាវនាវសុំឱ្យរដ្ឋាភិបាលអ៊ីតាលី បន្តផ្ដល់ជំនួយក្នុងការដោះកំចាត់មីននៅប្រទេសកម្ពុជា និងជួយជនរងគ្រោះដោយសារមិនព្រោះតែសង្គ្រាមជិតបីទសវត្សរ៍នេះផងដែរ ។ លើសពីនេះកញ្ញាក៏បានអំពាវនាវប្រទេសធំៗទាំងអស់ឈប់ផលិតគ្រាប់មីនតទៅទៀត ។


Photo : DR

សម្ដេចប៉ាបបេណេឌីកទី១៦ កំពុងស្វាគមន៍គណៈប្រតិភូនៃប្រទេសកម្ពុជាពេលទៅដល់អ៊ីតាលី

ដល់ឆ្នាំ២០០៩នេះ ប្រទេសដែលបានចុះហត្ថលេខាឈប់ប្រើប្រាស់គ្រប់មីន មានចំនួន ១៥៦ ប្រទេស ក្នុងនោះរួមមានទាំងប្រទេសកម្ពុជាផងដែរ ។

## សិក្ខាសាលាសមាគមគ្រូអប់រំជំនឿ

កាលពីថ្ងៃទី២០ ដល់២៤ខែមេសា សមាគមក្រុមគ្រូអប់រំជំនឿបានរៀបចំនូវសិក្ខាសាលាមួយលើប្រធានបទ : “ការលូតលាស់នៃវ័យ និងទំនាក់ទំនង” នៅក្រុងព្រះសីហនុ ដោយមានការណែនាំដោយអង្គការ ការ៉ូ និងសេដ្ឋា និងលោកគ្រូដួងសារង្សដែលជាគ្រូអប់រំជំនឿគ្រីស្ដបរិស័ទជាអ្នកសម្របសម្រួល ។

សិក្ខាសាលានេះក៏មានការពន្យល់អំពីសៀវភៅសម្ព័ន្ធមេត្រីថ្មី និងសម្ព័ន្ធមេត្រីចាស់ អំពីប្រវត្តិព្រះសហគមន៍ អគ្គសញ្ញា ទាំង៧ និងទំនាក់ទំនងរវាងបុរស និងស្ត្រីជាដើម ។

លោកគ្រូដួងសារង្ស បានគូសបញ្ជាក់ថា បងប្អូនដែលបានមកទទួលអប់រំជឿមានរបៀបទាក់ទងផ្សេងៗពីគ្នាតាមចិត្តសាស្ត្រនៃវ័យ ។ ដូច្នេះយើងត្រូវចេះ គរុកោសល្យអំពីរបៀបទំនាក់ទំនងដែលជាជំហានដំបូង ធ្វើឱ្យយើងកាន់តែស្គាល់គ្នាច្បាស់ឡើង ។

ក្នុងសិក្ខាសាលា ក៏មានចូលរួមចំនួន ៨០នាក់ មកពីព្រះសហគមន៍កាតូលិកភូមិភាគទាំង ៣ និងក្រុមការ៉ូ និងសេដ្ឋា ចំនួន១៥នាក់ ។

**តន**

## សម្ពោធព្រះវិហារព្រះសហគមន៍កោះរកាភូមិភាគកំពង់ចាម

កាលពីព្រឹកថ្ងៃទី១៧ មេសា ២០០៩ នៅព្រះសហគមន៍កាតូលិកកោះរកា ភូមិភាគកំពង់ចាម ប្រារព្ធពិធីសម្ពោធ ព្រះវិហាររបស់ខ្លួន ដែលមានឈ្មោះថា ព្រះវិហារសន្តហ្វ្រង់ស្វ័រ និងសន្តីក្លារ៉ា។

ពិធីនេះបានប្រារព្ធនៅក្រោមអធិបតីភាពរបស់លោកអភិបាលអន់តូនី លោកបូជាចារ្យ ដូនជី គ្រីស្តបរិស័ទមកពីភូមិផ្សេងៗ និងមានការចូលរួមពីចៅហ្វាយស្រុក មេឃុំ មេភូមិ ដែលមានប្រមាណជា ២០០នាក់។ ព្រះសហគមន៍កោះរកា បានកកើតឡើងតាំងពីឆ្នាំ១៩៩៦ និងមានយាយហួ ហ៊ីម ជាគ្រីស្តបរិស័ទដែលទទួលពិធីជ្រមុជទឹកដំបូងគេនៅឆ្នាំ១៩៩៩។ រហូតមកដល់សព្វថ្ងៃ មានគ្រីស្តបរិស័ទចំនួន ៦១នាក់។ លោកឪពុកសេរ៉ាលជាអ្នកទទួលខុសត្រូវព្រះសហគមន៍នេះបានកត់សម្គាល់ថា : “កត្តាដែលនាំឱ្យព្រះសហគមន៍នេះមានការរីកចម្រើន មាន ៣រួមផ្សំគ្នាឡើង ទី១ គឺអ្នកណែនាំព្រះសហគមន៍មានគំរូល្អ។ ទីពីរ គឺក្រុមយុវជនដែលចេះសាមគ្គីគ្នា និងមានការជឿជាក់លើព្រះសហគមន៍ និងកត្តាទី៣ គឺបងប្អូនយល់ថា ព្រះសហគមន៍ជារបស់ខ្លួនផ្ទាល់ ទោះបីមានពេលខ្លះ មិនមានវត្តមានលោកបូជាចារ្យ ក៏គេអាចរួមគ្នាប្រារព្ធពិធីបុណ្យ និងធ្វើសកម្មភាពផ្សេងៗបានដែរ។

**រ៉ូ បូរ៉ា**

## កម្មវិធី “ប្រវត្តិសាស្ត្រខ្មែរ” បង្ហាញដោយលោកប៉ុងសូជ៍

ថ្ងៃពុធ ទី**២៩ មេសា** ២០០៩ : ម៉ោង ១៨:៣០-ម៉ោង២០:០០ អំពី **“ប្រទេសកម្ពុជាចាប់ផ្ដើមកកើតដំបូងរហូតដល់សម័យអាណានិគម (១៩៥៣)”** ។ ថ្ងៃអង្គារ ទី**០៥ ឧសភា** ២០០៩ : ម៉ោង១៨:៣០-ម៉ោង ២០:០០ **“ព្រះរាជាណាចក្រកម្ពុជាទីមួយ (១៩៥៣-១៩៧០)”** ។ ថ្ងៃពុធ **ទី២០ ឧសភា** ២០០៩ : ម៉ោង១៨:៣០-ម៉ោង២០:០០ **“សាធារណៈរដ្ឋលន់ ណុល និងការកកើតគណបក្សកុំមុយនីស្ដកម្ពុជា (១៩៧០-១៩៧៥)”** ។ ថ្ងៃព្រហស្បតិ៍ **ទី២៨ ឧសភា** ២០០៩ : ម៉ោង១៨:៣០-ម៉ោង២០:០០ **“កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)”** ។ ថ្ងៃពុធ **ទី០៣ មិថុនា** ២០០៩ : ម៉ោង១៨:៣០-ម៉ោង២០:០០ **“សាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩-១៩៨៩)”**។ ថ្ងៃអង្គារ **ទី០៩ មិថុនា** ២០០៩ : ម៉ោង១៨:៣០-ម៉ោង២០:០០ **“ព្រះរាជាណាចក្រកម្ពុជាទីពីរ (១៩៩៣ រហូតមកដល់បច្ចុប្បន្ន)** ។

សិក្ខាសាលាទាំងនេះត្រូវបានរៀបចំឡើងសម្រាប់សាធារណជនទូទៅ ព្រមទាំងជនបរទេសផងដែរនៅក្នុងមណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក ហៅ ស៊ីអេសស៊ី ផ្ទះលេខ ២៥ ផ្លូវ ២៤២ បឹងព្រលឹត ៧មករា ភ្នំពេញ កម្ពុជា ។ ទូរស័ព្ទ : ០២៣ ២២៤ ១២០ ។ អ៊ីម៉ែល : **csccambodia@gmail.com** ។





# សកម្មភាពបង្ហាញវត្តមានព្រះជាម្ចាស់

**លី សុវណ្ណា**

នេះជាប្រសាសន៍លោកតេអូដរ ម៉ាកការីក ដែលជាទីប្រឹក្សាសម្ដេចប៉ាប ក្នុងពេលសំណេះសំណាល ជាមួយក្រុមប្រឹក្សាព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញកាលពីថ្ងៃទី២៩ មេសា កន្លងទៅ ។

ក្នុងការសំណេះសំណាលនេះ លោកមានប្រសាសន៍ថា ព្រះសហគមន៍បានរួបរួមគ្នា និងងើបឡើងវិញក្រោយពីសង្គ្រាម ក្នុងនោះគឺមានបងប្រុស បងស្រីដែលបំពេញកិច្ចការដោយត្រឹមត្រូវ និងពោរពេញដោយជំនឿដើម្បីជួយព្រះសហគមន៍ ។ លោករំឭកឡើងវិញអំពីអ្វីដែលលោកធ្លាប់ឮ និងជួប គឺលោកអ៊ីវ រ៉ាមូស អតីត អភិបាលព្រះសហគមន៍ ភូមិភាគភ្នំពេញ ដែលមានឈ្មោះល្បី និងជាមនុស្សដ៏ឧត្ដមដែលមានជំនឿយ៉ាងមាំមួន ។ លោកទីប្រឹក្សាក៏បានសរសើរលោកអេមីល ដេតម្ប អភិបាលព្រះសហគមន៍នៃភូមិភាគភ្នំពេញ ដែលបានខិតខំកសាងព្រះសហគមន៍កាតូលិកកម្ពុជា តាំងតែពីមុនឆ្នាំ១៩៧៥ ក្រោយឆ្នាំ១៩៨៩ ។ លោកទីប្រឹក្សា ក៏បានបញ្ជាក់ដែរពីសកម្មភាពក្រុមសាសនទូតក្រៅទីក្រុងប៉ារីស នៅទ្វីបអាស៊ី ដែលបានកសាងនូវព្រះសហគមន៍ជាច្រើន ក្នុងទ្វីបដ៏សំបូរបែបមួយនេះ ។ រួមជាមួយគ្នា លោកក៏មិនភ្លេចនូវសកម្មភាពរបស់ក្រុម គ្រួសារម៉ារីណុលដែល បានជួយកម្ពុជាផងដែរ ។


Photo : DR

លោកតេអូដរ ម៉ាកការីក ទីប្រឹក្សាសម្ដេចប៉ាប មកសួរសុខទុក្ខព្រះសហគមន៍កាតូលិកភ្នំពេញ (រូបកណ្ដាល)។

នាពិធីដ៏វិសេសនេះ លោកបានលើកទឹកចិត្តបងប្អូនទាំងអស់ ឱ្យរួមគ្នាបង្ហាញអំពីវត្តមាន របស់ព្រះជាម្ចាស់ក្នុងសកម្មភាពប្រចាំថ្ងៃរបស់ខ្លួន ហើយអង្វរព្រះជាម្ចាស់ឱ្យប្រទានជំនឿមាំមួនថែមទៀត ។

## ព្រះសហគមន៍កាតូលិក ភូមិភាគកំពង់ចាម

លោកអន់ជ្រេ ឡឺស្វែហ្វ ត្រូវបានសម្ដេចប៉ាបជ្រើសរើសជាអ្នកណែនាំ និងទទួលខុសត្រូវ លើភូមិភាគនេះក្នុងនាមព្រះអង្គមុនគេ កាលពីឆ្នាំ១៩៦៨ ។

ដោយសារប្រទេសកម្ពុជាជួបប្រទះសង្គ្រាម លោកអភិបាលអន់ជ្រេ ក៏ត្រូវគេបណ្ដេញ ចេញពីប្រទេសកម្ពុជា រួមនិងជនបរទេសផ្សេងៗទៀត ។

អំឡុងពីឆ្នាំ១៩៧៥ ដល់១៩៧៩ ព្រះវិហារនៃព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម ត្រូវពួកខ្មែរក្រហមបំផ្លាញចោលទាំងស្រុង ។ បងប្អូនគ្រីស្តបរិស័ទត្រូវបែកបាក់ខ្ចាត់ខ្ចាយ រស់នៅ ដោយគ្មានអ្នកណែនាំ និងខ្លះទៀតត្រូវបានសម្លាប់ផងដែរ ។

នៅឆ្នាំ១៩៩៣ នៅពេលប្រទេសជាតិទទួលបាននូវសន្តិភាព លោកអន់ជ្រេក៏បានវិលត្រលប់មកវិញ ។ ពេលមួយនោះ លោកបានឈរមុខផ្សារកំពង់ចាមពេញ ១ថ្ងៃ ដើម្បីស្វែងរកគ្រីស្តបរិស័ទ តែគ្មានបានផលអ្វីទេ ។ លោកត្រលប់មកភ្នំពេញវិញ ។ បន្ទាប់មកលោកទទួលលិខិតពីគ្រីស្តបរិស័ទម្នាក់ ។ លោកក៏ចាប់ផ្ដើមបេសកកម្មថ្មីពីពេលនោះ រហូតដល់ឆ្នាំ១៩៩៧ ។ នៅឆ្នាំ២០០០ លោកអន់តូនី សាមី ស៊ូសៃរាជ ទទួលភារកិច្ចបន្តរហូតដល់សព្វថ្ងៃ ។

ចាប់តាំងពីពេលនោះ ព្រះសហគមន៍បន្តរីកចម្រើនបន្តិចម្ដងៗ ក្រោមការណែនាំរបស់លោកអភិបាលដោយមានការចូលរួមអំពីលោកបូជាចារ្យ បងស្រី និងគ្រីស្តបរិស័ទ ។ ឥឡូវនេះភូមិភាគកំពង់ចាម គឺមានចំនួន ២០ព្រះសហគមន៍ ដែលមានគ្រីស្តបរិស័ទចំនួនប្រមាណ ២៧០០នាក់ ។ សកម្មភាពរបស់ព្រះសហគមន៍ភូមិភាគកំពង់ចាម ដែលមានធ្វើក្នុងសង្គម មានដូចជា មណ្ឌលយុវជន ការឧបត្ថម្ភដល់និស្សិតក្រីក្រតាមភូមិ ការផ្ដល់ការគាំទ្រថ្នាក់បំប៉ននៅពេលវិសមកាល មត្តេយ្យសាលា ការជួយដល់សាលាបឋមសិក្សា អនុវិទ្យាល័យ ការគាំទ្រចំពោះនិស្សិតក្រីក្ររៀននៅមហាវិទ្យាល័យ កម្មវិធីអប់រំកុមារតាមភូមិ ការជួយអ្នកជំងឺ ការបញ្ជូនទៅមន្ទីរពេទ្យ ព្រមទាំងសង្គ្រោះបន្ទាន់ជាដើម-ល- ។

តែនិយាយជារួមសកម្មភាពទាំងនេះ អាចប្រព្រឹត្តទៅបាន ក៏ដោយសារមានការសហការអំពីអង្គការកាតូលិករួមជាមួយគណៈកម្មការព្រះសហគមន៍ គណៈកម្មការសង្គហៈ គណៈកម្មការពិធីបុណ្យ និងគណៈកម្មការអប់រំជំនឿផងដែរ ។

ព្រះវិហារនៃព្រះសហគមន៍កាតូលិកកំពង់ចាម នៅក្រុងកំពង់ចាម ខេត្តកំពង់ចាម


Photo : L. Sovanna

## កាលបរិច្ឆេទកកើត

សម្ដេចប៉ាបប៉ូលទី៦ បានបង្កើតព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាមឡើង កាលពីថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ១៩៦៨ ដោយបានកាត់យកព្រះសហគមន៍កាតូលិកមួយចំនួនចេញពីព្រះសហគមន៍ភូមិភាគភ្នំពេញ។

ភូមិភាគព្រះសហគមន៍កាតូលិកកំពង់ចាមនេះ បានគ្របដណ្ដប់លើខេត្តចំនួន ៧ គឺមាន ខេត្តកំពង់ចាម ក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ព្រៃវែង និងខេត្តស្វាយរៀង។

## បទយកការណ៍រូបថត

# សកម្មភាពរបស់គ្រីស្តបរិស័ទក្នុងសប្តាហ៍ពិសិដ្ឋ

**លី សុវណ្ណា**

*សប្តាហ៍ពិសិដ្ឋត្រូវបានប្រារព្ធឡើងចាប់ពីថ្ងៃលើកតម្កើងថ្ងៃបុណ្យទុក្ខលំបាករបស់ព្រះយេស៊ូ (បុណ្យហែស្លឹក) រហូតដល់ថ្ងៃបុណ្យចម្លង ។*



Photo : L. Sovanna

គ្រីស្តបរិស័ទលាងជើងឱ្យគ្នាទៅវិញក្នុងពិធីព្រះយេស៊ូលាងជើងឱ្យក្រុមសាវ័កនាថ្ងៃព្រហស្បតិ៍ពិសិដ្ឋនៅព្រះសហគមន៍កំពង់ចាម



Photo : L. Sovanna

ពិធីបុណ្យហែស្លឹកនៅព្រះវិហារព្រះកុមារយេស៊ូ ព្រះសហគមន៍កាតូលិកបឹងទំពុន ក្នុងភូមិភាគភ្នំពេញ



Photo : BB

ថ្ងៃសុក្រពិសិដ្ឋ គ្រីស្តបរិស័ទសម្តែងកាយវិការរំឭកអំពីទុក្ខលំបាករបស់ព្រះយេស៊ូ នៅព្រះសហគមន៍បាត់ដំបង



Photo : Chamkar Teang

ពិធីគោរពព្រះឈើឆ្កាងព្រះយេស៊ូនៅថ្ងៃសុក្រពិសិដ្ឋ នៅព្រះវិហារសន្តី ម៉ារី ញញឹម ព្រះសហគមន៍ចំការទៀង



Photo : L. Sovanna

គ្រីស្តបរិស័ទទទួលភ្លើងថ្មី នៅព្រះសហគមន៍កាតូលិកកំពង់ចាម។ នេះជាសញ្ញាដែលព្រះយេស៊ូទទួលព្រះជន្មថ្មីដ៏រុងរឿង



Photo : L. Sovanna

ពិធីព្រះពរភ្លើងថ្មី នៅថ្ងៃបុណ្យចម្លង នៅព្រះសហគមន៍កាតូលិកក្រុងកំពង់ចាម



## បទយកការណ៍ព្រះសហគមន៍កាតូលិក

# ផលនៃសក្ខីភាពរបស់អ្នកមានជំនឿលើព្រះជាម្ចាស់

**លី សុវណ្ណា**

គ្រីស្តបរិស័ទគ្រប់រូបមាននូវតួនាទីដ៏សំខាន់ក្នុងការប្រកាសដំណឹងល្អ គឺអំពីសេចក្តីស្រឡាញ់របស់ព្រះយេស៊ូដល់មនុស្សទាំងអស់ ដោយគោរពសេរីភាពរបស់បងប្អូនទាំងអស់គ្នាផងដែរ ។

ជាក់ស្តែង ព្រះសហគមន៍កាតូលិកនៅក្នុងប្រទេសកម្ពុជាបានដើរតួយ៉ាងសំខាន់ក្នុងមុខងារនេះ ។ ព្រះសហគមន៍កាតូលិក ក៏បានឆ្លងកាត់នូវប្រវត្តិសាស្ត្រយ៉ាងលំបាកលំបិនរួមជាមួយប្រជាជនកម្ពុជា និងក៏បានចូលរួមស្ថាបនាសង្គមឡើងវិញដែរ តាមរយៈសកម្មភាពសង្គមនានា ស្របតាមយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។សកម្មភាពទាំងនេះស្តែងចេញពីជំនឿលើព្រះយេស៊ូគ្រីស្ត និងបានធ្វើឱ្យបងប្អូនជាច្រើនស្គាល់ព្រះយេស៊ូ ។កាលពីពេលបុណ្យចម្លងកន្លងទៅ ក៏មានអ្នកទទួលជ្រមុជទឹកថ្មី ចំនួន១៩៧នាក់ នៅក្នុងព្រះសហគមន៍កាតូ-លិកទាំងបីភូមិភាគ ។ ក្នុងនោះ ៥៨នាក់ គឺមាននៅព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម ។

លី ឈាងឡេង ជាម្នាក់ក្នុងបងប្អូនទាំងនោះ មកពីសហគមន៍អណ្តូងច្រោះ ស្រុកកំពង់សៀម រៀបរាប់ថា លោកក៏ទទួលជឿលើព្រះយេស៊ូដោយសារបានឃើញនូវសក្ខីភាព របស់បងប្អូនគ្រីស្តបរិស័ទ ដែលបានយកចិត្តទុកដាក់ចំពោះអ្នកក្រីក្រ អ្នកជំងឺ និងចាស់ជរាជាដើម ។ លោកក៏បានរំឭកឡើងវិញ ថាកាលពី៣ឆ្នាំមុន គ្រួសារលោកមានជំងឺទម្ងន់ ក៏ត្រូវសម្រាកព្យាបាលនៅមន្ទីរពេទ្យ ហើយបានបងប្អូនគ្រីស្តបរិស័ទ យកចិត្តទុកដាក់សួរសុខទុក្ខ ចែកថ្នាំឱ្យរហូតព្យាបាលបានជាសះស្បើយ ។បុរសវ័យ៣៩ឆ្នាំរូបនេះបន្តថា ពីមុនលោកក៏ធ្លាប់ឮគេនិយាយថាសាសនាថ្មីនេះធ្វើឱ្យមនុស្សវង្វេង គឺសូម្បីរូបលោកផ្ទាល់ ក៏មិនចូលចិត្តចំពោះ គ្រីស្តសាសនានេះដែរ ។ ប៉ុន្តែតាមរយៈការទទួលអប់រំ ធ្វើឱ្យលោកមានការកែប្រែ និងចេះយកចិត្តទុកដាក់ កាន់តែខ្លាំងឡើងចំពោះបងប្អូនក្នុងភូមិ ចេះលើកលែងទោស ឱ្យគេ និងបម្រើបងប្អូនឯទៀតៗផង ។ពាក្យដែលគេធ្លាប់និយាយ ទស្សនៈពុំល្អចំពោះគ្រីស្តសាសនា និងការរើសអើង ក៏ត្រូវប្តូរមកជារាប់អានគ្នាវិញ ។

សម្រាប់យុវជនដានី មកពីព្រះសហគមន៍កោះរកា ឃុំកោះខេត្តកំពង់ចាម បានរៀបរាប់ថា ប្អូនរីករាយណាស់ ដែលបានទទួលអគ្គសញ្ញាជ្រមុជទឹក ក្លាយជាគ្រីស្តបរិស័ទ និងទទួលជីវិតថ្មីពីព្រះយេស៊ូ ។ ប្អូនបានរំឭកពីការសម្រេចចិត្តនេះថា ដោយបានឃើញនូវគំរូរបស់បងៗជាគ្រីស្តបរិស័ទដែលតែងចំណាយពេលយកចិត្តទុកដាក់ចំពោះចាស់ជរា និងអ្នកក្រីក្រក្នុងភូមិ ប្អូនក៏សប្បាយ និងរំភើបចិត្ត ។ យុវជនវ័យ១៨ឆ្នាំរូបនេះបន្តថា ពេលនេះប្អូនទទួលព្រះបន្ទូលព្រះយេស៊ូ និងស្ម័គ្រចិត្តរស់នៅដោយបម្រើសកម្ម-ភាពសង្គមនានាតាមព្រះសហគមន៍កាតូលិក ។

លោកបូជាចារ្យ សេរ៉ាល់ វ៉ូសាំង តំណាងពេញសិទ្ធិលោកអភិបាលព្រះសហគមន៍កាតូលិកនៃភូមិភាគកំពង់ចាម បានទទួលស្គាល់ថា បងប្អូនទាំងនេះបានព្យាយាមរស់នៅតាមព្រះបន្ទូលដោយបម្រើបងប្អូនផ្សេងៗ និងសម្តែងថាគេជាគ្រីស្តបរិស័ទ។ គេមានចិត្តក្លាហានប្រកាសអំពីជំនឿរបស់ខ្លួន។ ទោះបីជាផ្លូវការ គេមិនទាន់ក្លាយជាគ្រីស្តបរិស័ទ តែពួកគេប្រកាសខ្លួនថា ជាគ្រីស្តបរិស័ទដោយអំណរ ។







Photos : L. Sovanna

May-2009.qxd 5/2/2009 9:45 AM Page 16



# បុង បុង : "ខ្ញុំជាបរទេស បងប្អូនទទួលខ្ញុំ និងទុកចិត្តខ្ញុំ..."

**លី សុវណ្ណា**



Photo : DR

លោកបុងបុង នៅក្នុងសកម្មភាពចុះសួរសុខទុក្ខបងប្អូនក្រីក្រដល់ផ្ទះ នៅក្នុងរយៈពេលដែលលោកបម្រើព្រះសហគមន៏កម្ពុជា

លោកបុងបុង ដែលមានឈ្មោះដើមយ៉ានឡេស្ទ័រ ជាបងប្រុសនៅក្នុងក្រុមសមាជិកបព្វជិតសហជីវិនព្រះយេស៊ូ។ លោកបានមកប្រទេសកម្ពុជា នៅចុងឆ្នាំ ២០០៧។ លោករៀនភាសាខ្មែរ និងបានទៅបម្រើការងារនៅខេត្តបាត់ដំបងនៅមណ្ឌលទទួលអ្នកជំងឺហៅពេទ្យឃាយជី និងកម្មវិធីអាហារូបករណ៏ ដល់កុមារ ដែលឪពុកម្តាយផ្ទុកមេរោគអេដស៍ និងជំងឺអេដស៏។ ក្នុងរយៈពេល ជាងមួយឆ្នាំកន្លងមកនេះ លោកបានខិតខំអស់ពីកម្លាំងកាយចិត្ត ដើម្បីបម្រើបងប្អូនជាអ្នកជំងឺក្រីក្រ។

បងប្រុសបព្វជិតរូបនេះ បានមានប្រសាសន៏ថា ក្នុងពេលដែលលោកបម្រើបងប្អូនក្នុងមណ្ឌលសម្រាប់ទទួលអ្នកជំងឺ នៅពេទ្យឃាយជី នៃព្រះសហគមន៏កាតូលិក បាត់ដំបង លោកក៏មានអារម្មណ៏ជិតស្និទ្ធយ៉ាងខ្លាំងជាមួយអ្នកជំងឺ និងបុគ្គលិកនៅមណ្ឌល។ លោករៀនពីសេចក្តីស្រឡាញ់ពីបងប្អូនទាំងនោះ។ លោកបុងបុង សង្កត់ធ្ងន់ថា : "ខ្ញុំគឺជាជនបរទេស។ បងប្អូនទទួលខ្ញុំ។ គេជួយខ្ញុំក្នុងការទំនាក់ទំនង ជាភាសាខ្មែរ ជាពិសេសបងប្អូនអត់ទោសឱ្យខ្ញុំនិងទុកចិត្តលើខ្ញុំ"។ គេទាំងអស់គ្នាផ្តល់សេចក្តីសង្ឃឹម និងលើកទឹកចិត្តខ្ញុំដែរ។

ជារៀងរាល់ឆ្នាំ ក្រុមបព្វជិតសហជីវិនព្រះយេស៊ូក៏តែងបញ្ជូននិស្សិតដែលជាបងប្រុសនៃក្រុមនេះមកបំពេញកិច្ចការបម្រើនៅប្រទេសកម្ពុជា ជាពិសេសជួយអ្នកក្រីក្រ និងជនពិការជាដើម។នៅក្នុងគោលបំណងទទួលបទពិសោធន៏ និងរិះគិតស៊ីជម្រៅ អំពីជីវិតខាងផ្លូវវិញ្ញាណក្នុងមុខងារជាអ្នកបម្រើ។ បងប្រុសបព្វជិត វ័យ ៣៤ឆ្នាំ រូបនេះ បញ្ជាក់ថា លោកទទួកយកគំរូយ៉ាងល្អពីដូនជី ដែលជាអ្នកទទួលខុសត្រូវក្នុងមណ្ឌលទទួលអ្នកជំងឺ ដោយការបម្រើបងប្អូនដោយទឹកចិត្តទំលំទូលាយ និងការអធិដ្ឋានទាក់ទងជាមួយព្រះជាម្ចាស់ក្នុងជីវិតជាអ្នកបួស។

ឆ្លងតាមរយៈបទពិសោធន៏ទាំងនេះ ជួយឱ្យបុងបុងយល់ច្បាស់ថា លោកនឹងក្លាយជាបូជាចារ្យក្នុងក្រុមបព្វជិតសហជីវិនព្រះយេស៊ូនៅពេលអនគត។

លោកបុងបុង នឹងចាកចេញពីកម្ពុជាដើម្បីទៅបន្តរៀនទេវវិទ្យារយៈពេល ៤ឆ្នាំទៀត ទើបបានទទួលការតែងតាំងជាបូជាចារ្យ។ លោកសន្យាក្នុងចិត្តថា នឹងបានវិញត្រឡប់មកប្រទេសកម្ពុជាវិញ ក្រោយការតែងតាំងជាបូជាចារ្យ។ លោករំភើបចិត្តពេលឮគ្រីស្តបរិស័ទម្នាក់នៅបាត់ដំបង និយាយថា : "ខ្ញុំរង់ចាំបុងបុង ក្លាយជាបូជាចារ្យ និងថ្វាយអភិបូជានៅបាត់ដំបង មុនពេលខ្ញុំស្លាប់"។

លោកបុងបុងគឺជាកូនប្រុសច្បងគេក្នុងចំណោមកូនប្រុសទាំងបួនក្នុងគ្រួសារគ្រីស្តបរិស័ទ កាតូលិកនៅប្រទេសហ្វីលីពីន។ លោកគឺជាវិស្វករអគ្គិសនី និងធ្លាប់មានមុខតំណែងខ្ពស់ផងដែរ ក្នុងក្រុមហ៊ុន។

## ប្រតិទិនអភិបូជា

- ភាសាខ្មែរ : ព្រះវិហារសន្តយ៉ូសែបភ្នំពេញ (០១២ ៧៨២ ២៤១) ថ្ងៃច័ន្ទ-សៅរ៍ : ព្រឹកម៉ោង៦។ ថ្ងៃអាទិត្យ : ម៉ោង ៨ព្រឹក និងម៉ោង៤រសៀល។
  -កំពង់សោម (០១៦ ៨៤០ ៥៤០) ថ្ងៃច័ន្ទ ថ្ងៃពុធ និងថ្ងៃសុក្រ : ល្ងាចម៉ោង៥។ ថ្ងៃអង្គារ ថ្ងៃព្រហស្បតិ៍ និងថ្ងៃសៅរ៍ : ព្រឹកម៉ោង៦។ ថ្ងៃអាទិត្យ : ម៉ោង ៨ព្រឹក។
  -សៀមរាប (០៦៣ ៩៦៥ ២៨០) ថ្ងៃអាទិត្យ : ម៉ោង៧:៣០ព្រឹក។ ថ្ងៃច័ន្ទ-ថ្ងៃព្រហស្បតិ៍ : ព្រឹក ៦:៣០ម៉ោង។ ថ្ងៃសុក្រ : ម៉ោង ៦:៣០ល្ងាច។
  -បាត់ដំបង (ពេទ្យឃាយជី) ថ្ងៃអាទិត្យ : ម៉ោង ៨:០០ព្រឹក។ ថ្ងៃច័ន្ទ : ល្ងាច៦:០០។ ថ្ងៃអង្គារ-សុក្រ : ម៉ោង៦:១៥ ព្រឹក។
- ភាសាបារាំង : Saturday of 1st week and 3rd week at 5:30pm; Sunday of 2nd and 4th week at 11:00 am; At St. Joseph Church, #1788B, NR5, PP.
- ភាសាអង់គ្លេស : - Phnom Penh : Sunday at 10: 00 am; at St. Joseph Church (#1788B, NR5, PP); Saturday at 5: 00 pm, at World Vision Cambodia (#2 St 71, PP); - Sihaknouk Ville : Sunday at 5:00 pm; # Catholic Church St.12 13 Mattapheap; H/P: 016 840 540 (Fr. Werachai); - Siem Reap : Saturday at 6:30 pm; #Catholic Church, No 027 East River Side Street. - Battambang : Saturday: at 6:00 pm at Battamabang Church (Pet Yeaychi), Rumchek 1, Rattanak, H/P: 012 911 147 (Fr. Totet).







Photo : P. Samphy

# ត្រុដិមានអត្ថន័យដូចម៉ុងសាយ

**ខាន់ ភីរម្យ**

របាំត្រុដិដែលគេឃើញមានលេងរៀងរាល់ពេលបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ គឺជារបាំដែលគេលេងដើម្បីកំចាត់នូវភាពចង្រៃ និងអពមង្គលទាំងឡាយ ដែលវាមានអត្ថន័យស្រដៀងនឹងការលោតម៉ុងសាយចិនដែរ។

លោកមាច បុណ្ណ ជាសាស្ត្រាចារ្យអមក្រុមជំនុំនៃវិទ្យាស្ថានពុទ្ធសាសនិកបណ្ឌិត្យ មានប្រសាសន៏ថា : "អត្ថន័យនៃការសម្តែងរបាំត្រុដិរបស់ខ្មែរនិងការលោតម៉ុងសាយពេលចូលឆ្នាំចិន គឺសឹងតែដូចគ្នា"។

លោកបានឱ្យដឹងដែរថា ម៉ុងសាយរបស់ជនជាតិចិន គេច្រើនលេង នៅមុន និងនៅក្នុងពេលដែលជនជាតិចិនរៀបចំបុណ្យចូលឆ្នាំថ្មីរបស់គេ។ ដោយឡែកចំពោះការសម្តែងរបាំត្រុដិវិញ គឺច្រើនធ្វើឡើងនៅពេលពលរដ្ឋខ្មែរទូទៅ ប្រារព្ធបុណ្យចូលឆ្នាំប្រពៃណីជាតិដូចគ្នា។ របាំត្រុដិជាប្រភេទរបាំប្រពៃណីជាតិមួយប្រភេទរបស់ជនជាតិខ្មែរដែលគេឃើញមានលេងនៅតាមមន្ទីរ ឬក្រសួងនានានៅក្នុងប្រទេសកម្ពុជា នៅក្នុងពេលដែលបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ នាពាក់កណ្តាលខែមេសាចូលមកដល់។

របាំនេះ គេសម្តែងឡើងជាមួយនិងវត្តមានមនុស្សមួយក្រុមធំ ដោយរួមទាំងមានភ្លេងបុរាណប្រពៃណីជាតិ និងចម្រៀងអមជាមួយថែមទៀតផង។ ដើម្បីសម្តែងរបាំនេះឡើង គេចាំបាច់ត្រូវការមានមនុស្សមិនតិចជាង១៥នាក់ទេ ក្នុងនោះ មានអ្នកសម្តែងជាសត្វក្ងោកមួយគូ សត្វប្រើសម្នាក់ ព្រានព្រៃម្នាក់ យក្សម្នាក់ ទម្បោងមួយគូ ព្រាយក្រចកវែងពីរនាក់ អ្នកកាន់ត្រុដិ៤នាក់ អ្នកច្រៀងម្នាក់ និងក្រុមភ្លេង មួយក្រុមទៀតដែលលេងកំដរពេលឈុតឆាករបាំ។

លោកមាច បុណ្ណ មានប្រសាសន៏បន្តថា របាំនេះគឺជារបាំ ដែលជនជាតិខ្មែរ បង្កើតឡើងតាំងពីជនជាតិខ្មែររស់នៅក្នុងខណៈជាកុលសម្ព័ន្ធ ហើយមិនទាន់រៀបចំជារដ្ឋគ្រប់គ្រងមកម្ល៉េះ។ របាំត្រុដិនេះបានឆ្លុះបញ្ចាំងអំពីជីវភាព និងដើមកំណើតខ្មែរដំបូង ពោលគឺតាំងពីពេលដែលមនុស្សខ្មែរបុរាណទើបតែវិវដ្តចេញមកពីសត្វបានបន្តិច។ យើងអាចយល់ដូច្នេះបាន ដោយសារទិដ្ឋភាពនៃការសម្តែងទាំងអស់ គឺហាក់បីដូចជាផ្សារភ្ជាប់នឹងធម្មជាតិស្ទើរតែទាំងអស់ ពោលគឺអត្ថន័យរបស់វា គឺដើម្បីបណ្តេញអ្វីដែលចង្រៃចេញដើម្បីឱ្យលាភនៃឆ្នាំថ្មីចូល។

លោកក៏បានបញ្ជាក់ថា : "យើងអាចឃើញច្បាស់នៅត្រង់ថា គ្រប់តួសម្តែងទាំងអស់គឺសុទ្ធតែពាក់ព័ន្ធទៅនឹងធម្មជាតិ និងជីវភាពរបស់មនុស្សនាសង្គមបុរាណ ក្នុងនោះអត្ថន័យសំខាន់របស់របាំ គឺបង្កប់នៅត្រង់ព្រានព្រៃដេញ និងបរបាញ់សត្វ"។

## អំណាន

### បើបេះដូងជាប់ឈាម




នេះ ជាប្រលោមលោកផ្នែកមនោសញ្ចេតនា ដែលបានតាក់តែងឡើងដោយអ្នកនិពន្ធយូ សុភា និងបោះពុម្ពផ្សាយដោយសមូហកម្មស្លាប ប៉ាកាយូ សុភា ក្នុងឆ្នាំ២០០៨។

រឿងប្រលោមលោកនេះ បានឆ្លុះបញ្ចាំងពីតថភាពសង្គមមួយចំនួន នាពេលបច្ចុប្បន្ននេះ។ ហើយតាមរយៈអំណានរឿងនេះ អ្នកអានក៏នឹងទទួលបានគំនិតមួយចំនួនសម្រាប់យកមករិះគិតពិចារណានៅលើទង្វើ និងហេតុផលជាច្រើនដែលបង្កឱ្យមានបញ្ហានៅក្នុងសង្គម។

សម្រាប់រឿងប្រលោមលោកនេះ អ្នកនិពន្ធបានតាក់តែងឡើងដោយមានចំណុចពិសេសមួយ គឺគាត់ចេះធ្វើឱ្យអ្នកអានឆ្ងល់ ហើយចង់តាមដានថា តើមកពីមូលហេតុអ្វីបានជាតួឯកស្រីដែលមានអត្តចរិតថ្លៃថ្នូរម្នាក់ បែរជាសុខចិត្តធ្វើឱ្យនារីដទៃម្នាក់ទៀតដែលនាងគោរពស្រលាញ់ត្រូវឈឺចាប់រហូតធ្លាក់ខ្លួនឈឺ?

កិច្ចសន្ទនាជាច្រើនរវាងតួអង្គ និងតួអង្គ បានញុំាងឱ្យខ្សែរឿងកាន់តែមានភាពរស់រវើកថែមទៀត។ រឿងនេះមានកម្រាស់១៣៤ទំព័រ ដែលធ្វើឱ្យអ្នកអានមិនធុញទ្រាន់។




### អាសម្លាញ់

នេះគឺជាចំណងជើងសៀវភៅរឿងសម្រាប់កុមារៗ ដែលគេរៀបរៀងឡើងដោយលោកទ្រីសម្ផស្ស ដែលជាអ្នកនិពន្ធ អ្នកគំនូរ និងក៏ជាអ្នករចនាទំព័រផងដែរ។

នៅក្នុងរឿងនេះមានតួអង្គឆ្មារសំខាន់ពីរ មួយឈ្មោះ អាខ្មៅ និងមួយទៀត ឈ្មោះ អាសម្បុរបី។ ពួកគេទាំងពីរ គឺជាមិត្តជិតខាងនឹងគ្នា ហើយស្រលាញ់គ្នាខ្លាំងណាស់ដែរ។ ប៉ុន្តែនៅថ្ងៃមួយ ភាពលោភលន់បានធ្វើឱ្យអាសម្បុរបីកេងចំណេញលើអាខ្មៅដែលជាមិត្តល្អរបស់ខ្លួន។ តើនាទីបំផុតអាសម្បុរបីនឹងទទួលបានលទ្ធផលយ៉ាងណា ?

រឿងនេះត្រូវបានសរសេរឡើងសម្រាប់កុមារដែលទើបនឹងចេះអានដំបូងៗ។ ឃ្លាឃ្លោងខ្លីៗ អក្សរធំៗនិងរូបភាពល្អៗ ដែលជួយសម្រួលជាច្រើន ដល់អំណានរបស់កុមារ។ ពួកគេនឹងបានកំសាន្តសប្បាយជាមួយនឹងដំណើររឿងនេះ ហើយជាមួយគ្នានេះដែរ ពួកគេក៏នឹងទទួលបានគំនិតមួយចំនួនបន្ថែមទៀត ដែលអាចទុកជាទុនសម្រាប់ការវិវឌ្ឍន៏នៃការរិះគិតពិចារណា។ រឿងនេះមានកម្រាស់ ២០ទំព័រ ដែលសមស្របបំផុតសម្រាប់និទានឱ្យកុមារស្តាប់។

**ម៉េង សុមនា**

## ប្រវត្តិសាស្ត្រ

# ហ្វីលីពីន ជាប្រជាជាតិសម្បូរកោះបំផុត

**ជាត សំភី**




Photos : DR

ចាប់តាំងពី៨០០០ឆ្នាំ មុនគ្រិស្តសករាជ រហូតដល់សតវត្សរ៍ទី១៣ នៃគ្រិស្តសករាជ មានការមកតាំងទីលំនៅជាបន្តបន្ទាប់ អំពីសំណាក់ប្រជាជននៃប្រជុំកោះម៉ាឡេស៊ី និងឥណ្ឌូណេស៊ី លើទឹកដីហ្វីលីពីន។ ពីសតវត្សរ៍ទី៩ដល់ទី១២ ហ្វីលីពីនមានទំនាក់ទំនងពាណិជ្ជកម្មជាមួយនិងចិននិងជប៉ុន និងទំនាក់ទំនងវប្បធម៌យ៉ាងរឹងមាំជាមួយ និងប្រទេសឥណ្ឌា តាមរយៈប្រទេសម៉ាឡេស៊ី និងឥណ្ឌូណេស៊ី។

នាឆ្នាំ១៥២១ លោកម៉ាសេឡង់បានរកឃើញប្រជុំកោះហ្វីលីពីននេះ។ នាឆ្នាំ១៥៦៥ ប្រទេសហ្វីលីពីនបានស្ថិតនៅក្រោមអធិបតេយ្យភាព របស់ប្រទេសអេស្ប៉ាញ។ រដ្ឋបាលរបស់អេស្ប៉ាញ បាននាំមកនូវការបង្រួបបង្រួមនយោបាយ នៅលើកោះហ្វីលីពីន ដែលមុននេះបន្តិចជាកោះ និងសហគមន៍ឯករាជ្យស្ថិតនៅដាច់ៗដោយឡែកពីគ្នា។ អេស្ប៉ាញ បាននាំមកនូវអារ្យធម៌បស្ចិមប្រទេស គឺដូចជា ក្រមច្បាប់ របៀបបោះពុម្ព និងប្រតិទិនជាដើម។

នៅឆ្នាំ១៨៩៦ ការបះបោលនៃក្រុមអ្នកជាតិនិយមបានផ្ទុះឡើង។ អ្នកជាតិនិយមចូសេ រីហ្សាល់ (José Rizal) ដែលនៅពេលនោះជានិស្សិតសិក្សានៅអេស្ប៉ាញក៏បានចូលរួមបំផុសចលនានៅអេស្ប៉ាញ ដើម្បីទាមទារឱ្យមានកំណែទម្រង់រដ្ឋាភិបាលអយុត្តិធម៌នៅហ្វីលីពីន និងការរំលោភបំពានចំពោះអ្នកកាន់សាសនាគ្រិស្ត។ ដោយមិនបានសម្រេច លោករីហ្សាល់បានត្រឡប់មកហ្វីលីពីនវិញ និងបានបំផុសឱ្យមានកំណែកទម្រង់ក្នុងស្រុក តែត្រូវបរាជ័យ។

ថ្ងៃទី១២ មិថុនា ឆ្នាំ១៨៩៨ សាធារណរដ្ឋហ្វីលីពីនទី១ បានបង្កើតឡើង ដោយលោកអាហ្គីណាល់ដូ។ ប៉ុន្តែត្រូវរលាយទៅវិញភ្លាម ដោយសារកងកម្លាំងអាម៉េរិក ហើយភ្លើងសង្គ្រាមរវាងកងទ័ពអាម៉េរិក និងអ្នកបដិវត្តហ្វីលីពីនបានឆាបឆេះឡើង។ អាម៉េរិកឈ្នះសង្គ្រាម និងគ្រប់គ្រងប្រទេសហ្វីលីពីន។

ពីឆ្នាំ១៩៤១ ដល់១៩៤២ ជប៉ុនក៏បានចូលគ្រប់គ្រងប្រជុំកោះហ្វីលីពីន។ ពីឆ្នាំ១៩៤៤ ដល់ឆ្នាំ១៩៤៥ ប្រទេសអាម៉េរិកបានវាយយកប្រទេសហ្វីលីពីនជាថ្មីវិញ។ ដើម្បីជាការសងគុណដល់ កងទ័ពហ្វីលីពីនដែលបានចូលរួមនឹងកងទ័ពអាម៉េរិក ក្នុងការវាយជប៉ុនពីឆ្នាំ១៩៤៤ ដល់១៩៤៥ ហ្វីលីពីនបានទទួលឯករាជ្យភាពពីអាម៉េរិកនាថ្ងៃទី៤ កក្កដា ១៩៤៦។ សាធារណរដ្ឋហ្វីលីពីនត្រូវបានប្រកាស។

ពីឆ្នាំ១៩៤៨ ដល់១៩៥៧ លោករ៉ាមូន ម៉ាកសេសេ បានបំបាត់ចោលសង្គ្រាមទ័ពព្រៃ និងការបះបោលរបស់ប្រជាកសិករដែលប្រកាន់យកលិទ្ធិកុំម្មុយនីស្ត និងបានក្លាយខ្លួនជាប្រធានាធិបតី នៅឆ្នាំ១៩៥៣។ គាត់បានធ្វើជាប្រធានសន្និសីទទីក្រុងម៉ានីលដែលឱ្យកំណើតដល់អង្គការសេអាតូ។

នាទសវត្សរ៍ទី៦០ និង៧០ គឺជាពេលដែលសេដ្ឋកិច្ចហ្វីលីពីនមានការរីកចម្រើន (ឈរលេខ២នៅអាស៊ីបន្ទាប់ពីជប៉ុន)។ ទោះជាយ៉ាងណាប្រទេសហ្វីលីពីនបានវិវត្តន៍ជាមួយនិងអស្ថេរភាពនយោបាយ ជាច្រើនលើក ច្រើនសា ការផ្តួលរំលំរដ្ឋាភិបាលដោយរដ្ឋប្រហារ និងបាតុកម្មតាមដងផ្លូវ របស់ប្រជាជនជាច្រើនលើកច្រើនសារហូតដល់បច្ចុប្បន្ន ដែលរាំងស្ទះមួយចំនួនដល់ការអភិវឌ្ឍន៍។

### ភូមិវិទ្យារបស់ប្រទេសហ្វីលីពីន



**ហ្វីលីពីនជារដ្ឋប្រជុំកោះនៃអាស៊ីអាគ្នេយ៍លើផ្ទៃដីទំហំ ៣០០ ០០០ គម^២។ មានប្រជាជន៩០,៥ លាននាក់។ រដ្ឋធានី គឺម៉ានីល។ ប្រជាជនហ្វីលីពីនប្រើប្រាស់ភាសាតាហ្គាឡុក (ពីលីពីណូ) និងអង់គ្លេស។ រូបិយវត្ថុ គឺប៉ីសូហ្វីលីពបុាំង។ ប្រជុំកោះនេះមានអាកាសធាតុត្រូពិច និងប្រមូលផ្តុំកោះទាំងតូចទាំងធំចំនួន ៧១០៧កោះ ហើយដែលពោរពេញទៅដោយភ្នំ និងភ្នំភ្លើង។ កោះធំបំផុតមានចំនួនពីរ គឺលូស៊ុន (Luçon) និងមីនដាណាវ(Mindanao) ដែលផ្តុំបានជា ២ភាគបីនៃទំហំផ្ទៃដី និងចំនួនប្រជាជន។ ប្រជាជនភាគច្រើនជាគ្រិស្តបរិស័ទកាតូលិក។ ប្រទេសហ្វីលីពីនជាប្រទេសកសិកម្មយ៉ាងសំខាន់ដោយមានកម្មសិទ្ធដីធំៗ។**



# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ

**ថ្ងៃអាទិត្យទី៤ ក្នុងរដូវបុណ្យចម្លង (ថ្ងៃទី០៣ ឧសភា ឆ្នាំ២០០៩)**

*"ព្រះយេស៊ូ ជាអ្នកគង្វាលដ៏ល្អ"* (យ៉ូហាន ១០:១១-១៨)

ថ្ងៃអាទិត្យនេះ ព្រះបន្ទូលដំណឹងល្អនាំឱ្យយើងរិះគិតអំពីជីវិតយើងម្នាក់ៗ។ យើងហៅខ្លួនឯងថាជាគ្រិស្តបរិស័ទ។ ក៏ប៉ុន្តែសេចក្តីបារម្ភចម្បងរបស់យើងមិនមែនអំពីព្រះយេស៊ូគ្រិស្តទេ គឺរបររកស៊ី។

ព្រះយេស៊ូបានប្រកាសថា ព្រះអង្គជាអ្នកគង្វាលដ៏ល្អដែលដឹកនាំយើងរាល់គ្នា។ ព្រះយេស៊ូមិនអាចជាយើងបានទេ ប៉ុន្តែជាមនុស្សម្នាក់ល្អម្នាក់។ នៅក្នុងអត្ថបទ psalm ១១៨ យើងអធិដ្ឋានថា ថ្មត្រូវបានបដិសេដដោយអ្នកសាងសង់ ប៉ុន្តែថ្មបានក្លាយជាសរសរគ្រឹះយ៉ាងរឹងមាំ។ ព្រះយេស៊ូគឺជាថ្មដែលគេបដិសេដ។ ព្រះយេស៊ូគឺជាសេចក្តីត្រូវការចម្បងសម្រាប់ជីវិតរស់នៅ។ យើងបានជ្រាបរួចមកហើយថា សន្ត Peter បានបដិសេដមិនទទួលស្គាល់ព្រះជាម្ចាស់។ ប៉ុន្តែក្រោយមកលោកបានកែប្រែចិត្តគំនិតបន្ទាប់ពីបានឃើញសិរីរុងរឿងរបស់ព្រះជាម្ចាស់។ សន្ត Peter បានយល់ថា អ្វីៗ គ្រប់យ៉ាងកើតឡើងដោយព្រះជាម្ចាស់។

សូមឱ្យបងប្អូនទទួលបានការបំភ្លឺផ្លូវពីព្រះជាម្ចាស់ ជាអ្នកគង្វាលដ៏ល្អ និងជាព្រះជាម្ចាស់ដែលមានសិរីរុងរឿងដ៏ខ្ពង់ខ្ពស់។ យើងរស់នៅក្នុងជីវិតប្រចាំថ្ងៃដោយព្រះនាមព្រះជាម្ចាស់។ នៅក្នុងព្រះនាមព្រះជាម្ចាស់ពិភពលោកត្រូវបានជួយសង្គ្រោះឱ្យបានជាសះស្បើយ រួមទាំងយើងគ្រប់គ្នាផងដែរ។

**ថ្ងៃអាទិត្យទី៥ ក្នុងរដូវបុណ្យចម្លង (ថ្ងៃទី១០ ឧសភា ឆ្នាំ២០០៩)**

*"ព្រះយេស៊ូជាដើមទំពាំងបាយជូរដ៏ពិត"* (យ៉ូហាន ១៥:១-៨)

ព្រះគម្ពីរដំណឹងល្អថ្ងៃនេះ និយាយពីផ្លែឈើដែលទទួលបានផលច្រើន។ ព្រះយេស៊ូចង់ឱ្យសិស្សសាវ័ក ទ្រង់បង្កើតផលសម្រាប់ព្រះរាជ្យព្រះជាម្ចាស់។ យើងមិនអាចបង្កើតផលដោយខ្លួនឯងបានទេ។ យើងត្រូវចេះជួយគ្នា និងរួបរួមគ្នានៅជុំវិញព្រះជាម្ចាស់។ ក្នុងប្រទេសកម្ពុជា ព្រះជាម្ចាស់គឺចង់ឱ្យយើងរាល់គ្នាកសាងព្រះសហគមន៍តាមរយៈបង្កើតផលគ្រិស្តបរិស័ទដោយការរួបរួមគ្នា។

ដើមទំពាំងបាយជូរណាដែលមិនមែនមកពីព្រះជាម្ចាស់ ផលក៏មិនល្អនោះដែរ។ តើយើងបង្កើតផលច្រើនដោយរបៀបណា ? តើយើងអាចក្លាយជាតំណាងឱ្យព្រះយេស៊ូដោយរបៀបណា ? ព្រះយេស៊ូដែលស្គាល់ខ្ញុំ និងខ្ញុំក៏ស្គាល់ព្រះអង្គ ដែលនឹងបង្កើតផលបានច្រើនអនេក។

**ថ្ងៃអាទិត្យទី៦ ក្នុងរដូវបុណ្យចម្លង (ថ្ងៃទី១៧ ឧសភា ឆ្នាំ២០០៩)**

(យ៉ូហាន ១៥:១៩-១៧) ព្រះបន្ទូលដំណឹងល្អថ្ងៃនេះ នាំឱ្យយើងអធិដ្ឋានដល់ព្រះជាម្ចាស់។ សូមឱ្យយើងមានចិត្តចេះស្រលាញ់គ្នាទៅវិញទៅមក និងចេះជួយអ្នកដទៃ ជាពិសេសអ្នកក្រីក្រ។

ព្រះយេស៊ូមានព្រះបន្ទូលថា: "ព្រះបិតាស្រលាញ់ខ្ញុំ។ ដូច្នេះខ្ញុំក៏ស្រលាញ់អ្នកដទៃដែរ។ ខ្ញុំក៏រស់នៅដោយសេចក្តីស្រលាញ់"។ អ្នករាល់គ្នានឹងរស់ដោយសេចក្តីស្រលាញ់ បើសិនអ្នករាល់គ្នាប្រព្រឹត្តិតាមវិន័យរបស់ខ្ញុំ។ វិន័យរបស់ខ្ញុំ គឺ"ស្រលាញ់អ្នកដទៃដូចខ្ញុំស្រលាញ់អ្នកដែរ"។

យើងអាចសួរខ្លួនឯងថាតើការរស់នៅគ្រួសាររបស់យើងសង្គមយើងនិងទំនាក់ទំនងមនុស្សបានឆ្លុះបញ្ចាំងអំពីសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ចំពោះយើងទេ ?

ព្រះគម្ពីរដំណឹងល្អរបស់សន្តប៉ូល ជំពូក១៥ និយាយថា "លាហើយ" ចំពោះមិត្តរបស់លោក។ ចូរប្រាប់ពួកគេថា ព្រះអង្គនឹងនៅជាប់ជាមួយពួកគេ។ តើយើងអាចដឹងថា ក្តីស្រលាញ់របស់យើងមានកម្រិតណា ?

**ថ្ងៃអាទិត្យទី៧ ក្នុងរដូវបុណ្យលើកតម្កើងព្រះជាម្ចាស់ (ថ្ងៃទី២៤ ឧសភា ឆ្នាំ២០០៩)**

(ម៉ាកុស ១៦:៣៥-២០) ក្នុងរដូវបុណ្យចម្លង មានស្ត្រីទៅកាន់ផ្នូរលាបប្រេងលើរាងកាយព្រះយេស៊ូ។ ប៉ុន្តែ ព្រះអង្គមិនបានគង់នៅទីនោះទេ។ ទេវទូតក៏បានប្រាប់ពួកគេថា ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ដូចព្រះអង្គបានប្រកាសនៅមុខសាវ័កព្រះអង្គ មុនដែលពេលព្រះអង្គសោយទិវង្គត និងបានណែនាំឱ្យទៅប្រាប់ Peter និងសាវ័កដទៃទៀតថា ព្រះអង្គនឹងជួបអ្នករាល់គ្នានៅកាលីឡេ។

កាលីឡេជាទីកន្លែងដែលព្រះយេស៊ូចាប់ផ្តើមជីវិតជាមនុស្ស។ នៅទីនោះព្រះយេស៊ូក៏បានប្រាប់សាវ័កព្រះអង្គឱ្យទៅប្រាប់មនុស្សទាំងអស់នៅលើផែនដីនេះ។ ព្រះគម្ពីរដំណឹងល្អរបស់ម៉ាកុសនិយាយថាសាវ័កទ្រង់ចេញទៅកាន់គ្រប់ទីកន្លែងដើម្បីផ្សព្វផ្សាយព្រះគម្ពីរដំណឹងល្អ។ យើងទាំងអស់គ្នាដឹងរួចហើយថា ព្រះអង្គបន្តកិច្ចការតាមរយៈយើងទាំងអស់គ្នានេះ។ ដូច្នេះយើងទាំងអស់គ្នាមានបេសកកម្មទៅកាន់គ្រប់ទីកន្លែងដើម្បីផ្សព្វផ្សាយដំណឹងល្អរបស់ព្រះជាម្ចាស់នៅលើពិភពលោកទាំងមូល។

*(អ្នកនាំសារ ខែឧសភា ២០០៩ - អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ / លោកបូជាចារ្យ អូម៉ែរ ហ្សឺរ៉ាល់ដូ)*

## យើងអាន



Photo: DR

**សួស្តីប្អូនៗ**

កន្លងមកនេះ យើងបានប្រារព្ធបុណ្យព្រះយេស៊ូទទួលព្រះជន្មដ៏រុងរឿងពីព្រះបិតាបន្ទាប់ពីព្រះអង្គរងទុក្ខលំបាក និងសោយទិវង្គតនៅលើឈ្កាង។ តើប្អូនៗអាចនិទានរឿងឡើងវិញខ្លះបានទេ ? តើអ្នកណាទទួលដំណឹងមុនគេថា ព្រះយេស៊ូមិនមែនស្លាប់រហូតនោះ ?

តាមគម្ពីដំណឹងល្អ បានសរសេរថា ក្រោយពីព្រះយេស៊ូសោយទិវង្គត បីថ្ងៃ គឺនៅថ្ងៃអាទិត្យជាថ្ងៃបុណ្យចម្លង តាមប្រពៃណីជនជាតិអ៊ីស្រាអែល។ ស្ត្រីដែលបានស្រឡាញ់ និងដើរតាមព្រះយេស៊ូរហូតមក បានទៅកាន់ផ្នូររបស់ព្រះអង្គ ហើយពួកនាងបានឃើញផ្នូរនោះរបើក ហើយបាត់សាកសព។

ប្អូនៗសាកគិតមើល តើមានរឿងអ្វីកើតឡើងនៅពេលនោះ ? គឺទេវទូតរបស់ព្រះជាម្ចាស់បានបង្ហាញខ្លួនឱ្យពួកនាងឃើញ ដោយប្រាប់ថាព្រះជាម្ចាស់បានប្រោសព្រះអង្គឱ្យមានព្រះជន្មដ៏រុងរឿង ហើយព្រះយេស៊ូមិនគង់នៅកន្លែងមនុស្សស្លាប់នោះទេ។ ដំណឹងនេះធ្វើឱ្យពួកនាងត្រេកអរ ហើយទៅប្រាប់ក្រុមគ្រិស្តទូតឯទៀតៗ។ លោកយ៉ូហាន និងសិលាបានទៅមើល ក៏ឃើញដូចពួងនាងដែរ។ ពួកគ្រិសទូតនៅតែភ័យខ្លាច គឺភ័យខ្លាចគេចាប់យកទៅសម្លាប់ដូចព្រះយេស៊ូដែរ។ ពួកគេមិនបង្ហាញខ្លួននៅតាមទីសាធារណៈទៀតទេ គឺនៅសម្ងំតែក្នុងផ្ទះ។ ព្រះយេស៊ូបង្ហាញខ្លួនឱ្យពួកគេឃើញជាបន្តបន្ទាប់ ទើបគេមានចិត្តក្លាហានចេញទៅប្រកាសដំណឹងល្អថា ព្រះយេស៊ូទទួលព្រះជន្មថ្មីដ៏រុងរឿង គឺព្រះអង្គមិនស្លាប់នោះទេ។ ព្រះអង្គជាព្រះអង្គជាព្រះបុត្រារបស់ព្រះជាម្ចាស់។ ពួកគេចេញប្រកាសដំណឹងល្អពាសពេញពិភពលោកទាំងមូល។ ហេតុនេះហើយបានជាដំណឹងល្អនេះបានមកដល់យើងសព្វថ្ងៃនេះ។ ក្នុងនោះដែរមានមនុស្សជាច្រើនបានបូជាជីវិតដើម្បីដំណឹងល្អនេះ។ សូមប្អូនសាកល្បងរៀបរាប់ឈ្មោះអស់លោកដែលប្អូនបានស្គាល់ ហើយបានទទួលមរណភាពដោយសារជំនឿនៅប្រទេសកម្ពុជា និងនៅប្រទេសផ្សេងៗទៀតដែរទៅមើល។

លី សុវណ្ណា

# កំប្លែង និងពាក្យបណ្ដៅ

**កំប្លែង**

- ស្ដាប់ម៉ែណា! ប្រសិនបើកូនស្លូតបូត កូននឹងបានទៅឋានសួគ៌ៗ ប៉ុន្ដែប្រសិនបើកូនច្រឡើសបើស កូននឹងចុះទៅឋាននរក...
- ហើយចុះទៅមើលកុន?

**ពាក្យបណ្ដៅ**

តើសមុទ្រណាប្រៃជាងគេ?

- ❖ សមុទ្រក្រស័យ
- ❖ សមុទ្រក្រហម
- ❖ សមុទ្រខ្មៅ

**កំប្លែង**

- ខ្ញុំចេះហែលទឹកហើយ!
- ល្អណាស់តុំ! ឥឡូវយើងអាចទៅលេងបឹងទាំងអស់គ្នាបានហើយៗ
- ម៉ាក់ ខ្ញុំចេះហែលទឹក ប៉ុន្ដែខ្ញុំអត់ចេះបើកបរទេ!

**ពាក្យបណ្ដៅ**

តើអ្វីដែលមានធ្មេញ តែខាំមិនកើត?

**កំប្លែង**

- តើឯងប្រើដៃណាសម្រាប់សរសេរ?
- ប្រើដៃខ្ញុំ...!

**ពាក្យបណ្ដៅ**

តើអ្វីដែលឆ្លងកាត់កញ្ចក់បង្អួចបាន ដោយមិនឱ្យបែកកញ្ចក់?

**កំប្លែង**

- ខ្ញុំពិបាកចិត្តណាស់ ព្រោះឆ្កែខ្ញុំបាត់ហើយៗ
- ឯងគ្រាន់តែផ្សាយដំណឹងនៅក្នុងកាសែតទៅជាការស្រេចហើយៗ
- ប៉ុន្ដែ... ឆ្កែខ្ញុំអត់ចេះអានផង!

**ពាក្យបណ្ដៅ**

ឡានមួយបើកក្នុងល្បឿន ១០០គម ក្នុងមួយម៉ោងៗ តើកង់មួយណាដែលវិលយឺតជាងគេ?

**ពាក្យបណ្ដៅ**

តើផ្កាយអ្វីដែលនៅជិតផែនដីជាងគេ?

សូមថ្លែងអំណរគុណដល់អង្គការស៊ីប៉ាដែលជួយឧបត្ថម្ភទំព័រនេះ។
អង្គការស៊ីប៉ា: ប្រអប់សំបុត្រ ៣១ ផ្ទះលេខ៩ ផ្លូវ២១ រាជធានីភ្នំពេញ_កម្ពុជា ឬទូរស័ព្ទ: ០២៣ ២១៦ ០០១។

## កម្មវិធីវិទ្យុ "ខ្ញុំត្រូវការអ្នក"

ជាកម្មវិធីមួយដែលរៀបចំឡើងដោយការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក ដើម្បីជាការបង្ហាញផ្លូវ និងជួយស្វែងរកដំណោះស្រាយដល់មិត្តយុវវ័យ ដែលជួបប្រទះលើបញ្ហាមួយចំនួន មានដូចជា បញ្ហាសង្គម ចិត្តសាស្ត្រ និងទំនាក់ទំនងយុវវ័យ-ល-។ កម្មវិធីនេះមានការផ្សាយផ្ទាល់រាល់ថ្ងៃច័ន្ទ និងអង្គារ វេលាម៉ោង ១០-១១ព្រឹក នៅវិទ្យុគ្រួសារ **FM 99.5 Mhz** រាជធានីភ្នំពេញ ។

## ការងារប្រចាំខែ

- ថ្ងៃទី១-៣ ឧសភា: សំណាក់ធម៌ក្រុមរ៉ាំងសង់ ជីប៉ូល នៃភូមិភាគកំពង់ចាមនៅក្រុងព្រះសីហនុ ដែលមានសមាជិកចំនួន៥០នាក់ ដឹកនាំដោយលោកផាន ប៊ូរ៉ា ជាប្រធានក្រុម។
- ថ្ងៃទី៥ ឧសភា: ពិធីថ្វាយអភិបូជារបស់លោកបូជាចារ្យវ៉ង់ឌីណូ និងលោកបូជាចារ្យវិនសេដម្រាបលាទៅបារាំង ដែលដឹកនាំដោយលោកអភិបាលអេមីល ដេតម្ប៉នៅផ្សារតូច។
- ថ្ងៃទី៥-៧ ឧសភា: សិក្ខាសាលានៅទេវ-វិទ្យាល័យអំពីវប្បធម៌ទូទៅក្រោមការណែនាំរបស់លោកអភិបាលជនជាតិឥណ្ឌា ថូម៉ាស ម៉េណាប៉ារ៉ានទីល។
- ថ្ងៃទី៥ ឧសភា: សំណាក់ធម៌របស់ក្រុមបូជាចារ្យនៅភូមិភាគភ្នំពេញ ដែលរៀបចំធ្វើនៅព្រះវិហារសន្តយ៉ូសែប ហៅផ្សារតូច។
- ថ្ងៃទី១០ ឧសភា: កម្មវិធីបរិច្ចាគឈាមនៅព្រះវិហារព្រះកុមារយេស៊ូនៃព្រះសហគមន៍កាតូលិកបឹងទំពុន រាជធានីភ្នំពេញ។
- ថ្ងៃទី១៧ ឧសភា: ដំណើរកំសាន្ដរបស់បងប្អូនគ្រីស្ដបរិស័ទ នៅព្រះវិហារព្រះកុមារយេស៊ូទៅព្រះវិហារខេត្តកំពង់ឆ្នាំង ក្រោមការដឹកនាំដោយព្រះសហគមន៍កាតូលិកបឹងទំពុន។
- ថ្ងៃទី២០-២១ ឧសភា: សិក្ខាសាលារវាងពុទ្ធសាសនា និងគ្រីស្ដសាសនានៅក្រុងព្រះសីហនុ ដែលណែនាំដោយលោកបូជាចារ្យសេរ៉ាល់ និងបងស្រីសង្វាត ហើយដែលអ្នកចូលរួមទាំងអស់មានចំនួនពី៥០ ទៅ៦០នាក់។
- ថ្ងៃទី៣១ ឧសភា: ពិធីលាបថ្វាសនៅក្រុងព្រះសីហនុដល់អ្នកស្វែងយល់ចំនួន ២០នាក់។
- ថ្ងៃទី៣១ ឧសភា: កម្មវិធីលាបថ្វាសនៅកំពត សម្រាប់អ្នកស្វែងយល់ចំនួន ១៧នាក់។
- ថ្ងៃទី៣១ ឧសភា: បងប្រុសផុងផាន ផុកថាវី ដែលទើបនឹងតែងតាំងជាបូជាចារ្យ ថ្វាយអភិបូជាលើកដំបូងនៅព្រះសហគមន៍សន្តយ៉ូសែបហៅផ្សារតូច វេលាម៉ោង ៨ព្រឹក។
- ថ្ងៃទី៣១ ឧសភា: ពិធីលាបថ្វាសនៅព្រះវិហារព្រះកុមារយេស៊ូនៃព្រះសហគមន៍កាតូលិកបឹងទំពុន ដល់អ្នកស្វែងយល់ចំនួន៨នាក់ ដោយលោកអភិបាលអេមីល ដេតម្ប៉។
- ថ្ងៃទី១៨-១៩ កក្កដា: សិក្ខាសាលាអំពីចិត្តគំនិតនៃអ្នកអប់រំជំនឿចូលរួមពីភូមិភាគភ្នំពេញ និងកំពង់ចាម ដែលមានអ្នកចូលរួមចំនួន៥០-៦០នាក់ ដែលរៀបចំធ្វើឡើងនៅកំពង់ចាម។